បួត សេងគៀ

# រើសមក ទុកវិញ



កម្រងសំណេរខ្លីៗរបស់ខ្ញុំ
នៅលើហ្វេសប៊ុក

មាតិកា


| | |
|---|---|
| ទំព័រដើម | 1 - 2 |
| ខ្ញុំ និង I Like Samkok | 3 - 4 |
| សំណេរខ្លះៗក្នុងឆ្នាំ 2016 | 5 - 74 |
| ទំព័រចុងក្រោយ | 75 - 76 |
| អំពីខ្ញុំ | 77 |

# ទំព័រដើម

ខ្ញុំបង្កើតសៀវភៅនេះឡើង ដើម្បីទុកជាការចងចាំរបស់ខ្ញុំខ្លួនឯង និងអ្នកដែលធ្លាប់ចូលរួមជាមួយនឹង Page I Like Samkok ពីមុនដែរ។ ខ្ញុំមិនចង់ឱ្យអ្វីដែលខ្ញុំសរសេរបាត់ទៅទាំងស្រុងនោះទេ ហេតុនេះទើបខ្ញុំសម្រេចចិត្តថា ចំណាយពេលប៉ុន្មានដើម្បីដកស្រង់សំណេរខ្លះៗនៅលើ Page មកបញ្ចូលនៅក្នុងនេះ។

មេរៀនមួយដែលខ្ញុំរៀនចេះពីមុខវិជ្ជាក្រាហ្វិចឌីហ្សាញ គឺយើងអាចយកអ្វីដែលយើងធ្វើពីមុន មកច្នៃឡើងវិញបាន។ ការសរសេរក៏ដូចគ្នាដែរ ព្រោះយើងអាចនឹងគាំងគំនិតនៅពេលណាមួយ ក៏ថាបាន។ ការដែលមានរបស់មើលស្រាប់បែបនេះ ជារឿងល្អសម្រាប់អ្នកសរសេរស្ទើរៗដូចខ្ញុំ។

សៀវភៅនេះ មិនមែនជាសៀវភៅទ្រឹស្តី ឬវិធីសាស្ត្រពិសេសទេ។ វាគ្រាន់តែជាអ្វីដែលខ្ញុំសរសេរលេងពីមុនប៉ុណ្ណោះ។ កន្លែងខ្លះក៏សមហេតុផលទៅ កន្លែងខ្លះក៏ឆ្គងទៅ។ ខ្ញុំសរសេរដើម្បីបញ្ចេញគំនិតរបស់ខ្ញុំមកខាងក្រៅប៉ុណ្ណោះ ហើយខ្ញុំក៏មិនបានខ្វល់ច្រើនដែរនៅពេលសរសេរនោះ។

សៀវភៅនេះនឹងត្រូវដាក់ឱ្យដោនឡូដដោយសេរី សម្រាប់អ្នកដែលគាំទ្រសៀវភៅរបស់ខ្ញុំកន្លងមក ជាពិសេសអ្នកដែលស្គាល់ I Like Samkok តែម្តង។ ក្នុងនេះមានរហូតដល់ ២៣៣ចំណុច ដែលជាតំណាងឱ្យ post ទាំង ២៣៣ នៅលើ page។ ខ្ញុំមិនបានដាក់បញ្ចូលទាំងអស់នោះទេ ព្រោះចំណុចខ្លះទាក់ទងនឹងរឿងសាមកុកច្រើនពេក ដូច្នេះខ្ញុំមានសៀវភៅផ្សេងសម្រាប់ពួកវារួចហើយ។

សម្រាប់ការអានវិញ គឺយើងអានបកក្រោយ ដោយដេញពីចុងឆ្នាំ ២០១៦ ទៅដើមឆ្នាំវិញ។ បើយើងប្រៀបធៀបទៅ ប្រធានបទដែលខ្ញុំលើកឡើងមកសរសេរ គឺនៅម៉្លុំគ្នាវាហ្នឹងឯង គ្រាន់តែខ្ញុំចូលចិត្តសរសេរឆ្លាស់គ្នាចុះឡើងប៉ុណ្ណោះ។

ខ្ញុំសង្ឃឹមថា អ្នកទាំងអស់គ្នានឹងទាញបានប្រយោជន៍ខ្លះពីក្នុងសៀវភៅនេះចុះ ព្រោះបើអានចប់ហើយ បែរជាគ្មានបានអីត្រលប់ទៅវិញ ការអាននោះ ជារឿងខាតពេលមួយហើយ។ បើសិនជាមានចម្ងល់អី អាចចូលមកសួរខ្ញុំបាននៅលើ Page ហ្វេសប៊ុករបស់ខ្ញុំតែម្តង។

ខែ២២ ខែតុលា ឆ្នាំ២០១៦

ហួត សេងគៀ

# ខ្ញុំ និង I Like Samkok

ខ្ញុំបង្កើតផេកនេះឡើង កាលពីឆ្នាំ២០១៣ គឺក្រោយខ្ញុំមើលរឿងសាមកុកបានប៉ុន្មានដង។ ខ្ញុំចាប់អារម្មណ៍នឹងជាមួយការប្រើពាក្យ និងទ្រឹស្តីល្អៗជាច្រើននៅក្នុងរឿង ហើយគិតថា អ្នកដទៃដែលមិនទាន់បានមើលរឿងនេះក៏គួរតែដឹងពីចំណុចល្អនេះដែរ។ ខ្ញុំក៏ចាប់ផ្តើមដកស្រង់ចំណុចល្អៗទុកហើយធ្វើជារូបភាព និងសរសេរពន្យល់ខ្លី ហើយផុសនៅលើផេកនេះ។

ពីដំបូង គ្មានអ្នកណាគេចូលមើលទេ តែក្រោយមក ក៏ចាប់ផ្តើមមានគេចាប់អារម្មណ៍ដែរ។ I Like Samkok ខុសពីផេកសាមកុកដទៃទៀត ត្រង់ខ្ញុំមិនចំណាយពេលសួរពីសំណួរអត់ប្រយោជន៍ ដូចជា “បើសិនជាឱ្យរើសទីប្រឹក្សាដើម្បីចេញច្បាំង តើអ្នកយកអ្នកណាខ្លះ” ឬ “តើអ្នកណាស្អាតជាងគេក្នុងរឿង” នោះទេ។ ខ្ញុំចង់ឱ្យអ្នកដែលអានផេករបស់ខ្ញុំ មានពេលគិតទៅលើសម្តី ឬស្ថានការណ៍ណាមួយក្នុងរឿងប៉ុណ្ណោះ។ ភាគច្រើន គឺខ្ញុំប្រើរបៀបវិភាគរឿងដែលខ្ញុំធ្លាប់រៀនក្នុងមុខវិជ្ជាអក្សរសាស្ត្រ។

ខ្ញុំប្រើឈ្មោះជាអ្នកនិពន្ធដែលគ្មានអ្នកណាស្គាល់នេះមកធានា ថាខ្ញុំមិនដែលផុសអ្វីដែលធ្វើឱ្យអ្នកដទៃខាតពេលនោះទេ។ រាល់ការផុសរបស់ខ្ញុំ សុទ្ធតែមានគោលបំណងអ្វីមួយទាំងអស់។ ខ្ញុំមិនដែលខ្វល់ពីការ Like ឬ Share ទេ អ្វីដែលខ្ញុំខ្វល់ គឺតើវាមានប្រយោជន៍ ឬអត់ប៉ុណ្ណោះ។ យើងអាចទៅមើលផេកសាមកុកផ្សេងទៀតបាន ព្រោះគេមានវិធីទាក់ទាញអ្នកអានល្អជាងខ្ញុំ។ គេសួរជាសំណួរងាយៗ ដើម្បីបានចម្លើយច្រើន។ ខ្ញុំសួរសំណួរពិបាកដែលគ្មានអ្នកណាខ្វល់ ហេតុនេះទើបគ្មានគេស្គាល់ផេករបស់ខ្ញុំ។

I Like Samkok ជាកន្លែងដែលខ្ញុំរៀនសរសេរ ជាកន្លែងដែលខ្ញុំស្គាល់អ្នកដទៃដែលចូលចិត្តរឿងសាមកុក ហើយក៏ជាកន្លែងដែលខ្ញុំប្រាប់គេថា ខ្ញុំជាអ្នកសរសេរសៀវភៅម្នាក់ដែរ។ ខ្ញុំរៀនបានច្រើនពីការធ្វើផេកនេះ ជាពិសេស គឺបានស្គាល់ពីប្រភេទមនុស្ស។ ខ្ញុំមានរឿងច្រើនជាមួយអ្នកដទៃ ហើយខ្ញុំក៏មិនដែលខាំមាត់ទ្រាំដែរ។ បើគេមកភ្លើដាក់ខ្ញុំមុន ខ្ញុំនឹងជះកំហឹងទាំងអស់ទៅវិញមិនខាន។ ខ្ញុំមិនទ្រាំដោយសារតែមនុស្សដែលខ្ញុំមិនស្គាល់ម្នាក់ ហើយត្រូវពិបាកក្នុងខ្លួននោះទេ។ ខ្ញុំមិនទុកកំហឹងក្នុងខ្លួនទេ ដូច្នេះ អ្នកណាធ្វើ ទទួលយកទៅវិញទៅ។

ខ្ញុំធ្វើផេកនេះប្រហែលជាបីឆ្នាំហើយ ទើបខ្ញុំគិតថា មិនបាច់ធ្វើបន្តទៀតទេ ព្រោះវាគ្មានប្រយោជន៍។ ខ្ញុំមានផេកផ្ទាល់ខ្លួនទៅហើយ ហេតុអីចាំបាច់មានផេកច្រើនធ្វើអី។ ក្រោយឈប់ធ្វើផេកមួយ ខ្ញុំក៏បានសៀវភៅមួយក្បាលថ្មីដែរ។ ខ្ញុំគិតថា គ្មានអ្វីខាតទេ។

# សំណេរខ្លះៗក្នុងឆ្នាំ ២០១៦

## ថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ ២០១៦

*នេះជាថ្ងៃចុងក្រោយដែលខ្ញុំ post នៅលើផេកនេះ*

១ - យើងអាចជ្រើសយកការពិត ឬកុហកខ្លួនឯងដូចមនុស្សភាគច្រើន។

២ - ពេលខ្លះយើងរើខ្លួនមិនរួច ជាកំហុសរបស់យើងខ្លួនឯង។

៣ - កុំស្តាប់អ្នកណាដែលប្រកាសថាខ្លួនឯងដឹងច្បាស់គ្រប់រឿង។ យើងមិនអាចប្រាកដបានគ្រប់រឿងទេ។

## ខែសីហា ឆ្នាំ ២០១៦

៤ - អ្នកខ្លះចំណាយពេលពេញមួយជីវិត ទើបដឹងថាខ្លួនកំពុងត្រូវគេបោកប្រើ ឬកំពុងត្រូវគេគ្រប់គ្រង។ មូលហេតុ គឺដោយសារតែមិនជឿពេលមានគេប្រាប់ពីរឿងនេះកាលពីក្មេង។ ដោយសារមានអំណួតលើខួរក្បាលរបស់ខ្លួនឯងពេកដោយគិតថា គ្មានអ្នកណាបោកប្រើ ឬគ្រប់គ្រងខ្លួនបាន។

៥ - យើងត្រូវបង្រៀនខ្លួនឯងឱ្យបានល្អបំផុត ដើម្បីអ្វីដែលយើងចង់បាន។ បើយើងចង់បានថ្វីមាត់ល្អ យើងត្រូវជម្រុញខ្លួនឯងឱ្យរៀននិយាយជាប្រចាំជាមួយមនុស្សផ្សេងគ្នា។ បើយើងចង់បានរាងកាយរឹងមាំ ត្រូវជម្រុញខ្លួនឯងឱ្យហាត់ប្រាណជារៀងរាល់ថ្ងៃ ទោះបីយើងឈឺខ្លួនក៏ដោយ។ បើយើងចង់ជៀសផុតពីការបោកប្រាសរបស់សាសនា និងអ្នកនយោបាយ យើងត្រូវជម្រុញខ្លួនឯងឱ្យស្រាវជ្រាវ និងប្រើខួរក្បាលឱ្យបានគ្រប់ពេល។ គ្រប់

យ៉ាងគឺងាយស្រួលបែបនេះ ព្រោះខ្លួនយើងជាអ្នកសម្រេច និងធ្វើទាំងអស់។

៦ - បើយើងអាចជួយខ្លួនឯងបាន យើងក៏អាចជួយអ្នកដែលពិបាកដទៃទៀតបានដែរ។ បើយើងខ្លួនឯងលីលើមិនដឹងដើរទៅទិសណា យើងអាចនឹងនាំអ្នកដទៃវង្វេងតាមយើងក៏ថាបាន។

៧ - យើងត្រូវការពាក្យសរសើរជាច្រើន ដើម្បីធ្វើឱ្យមនុស្សម្នាក់មានជំនឿចិត្ត តែយើងត្រូវការពាក្យរិះគន់តែមួយ ឬពីរប៉ុណ្ណោះដើម្បីបំបាក់ទឹកចិត្តមនុស្សម្នាក់។

៨ - មនុស្សកំសាក ខ្លាចការពិត ចូលចិត្តទម្លាក់កំហុសឱ្យអ្នកដទៃ ខ្លាចចាញ់គេ តែមិនប្រឹង ជាមនុស្សហៃអើ ធ្វើអីមិនបានសម្រេច និងគ្មានសមត្ថភាពរកលុយដោយត្រឹមត្រូវ។

៩ - កុំរស់នៅដោយធ្វើជាមនុស្សកំសាកដូចគេដូចឯង។

១០ - តើយើងមើលទូរទស្សន៍ដើម្បីអ្វី? ដើម្បីឱ្យគេពង្វក់ ឬដើម្បីឱ្យខ្លួនឯងគេចវេសពីបញ្ហា? មិនមែនទាំងពីរ គឺមើលដើម្បីសម្រាកខួរក្បាល ប៉ុន្តែត្រូវចាំថាអ្វីដែលយើងមើល មិនពាក់ព័ន្ធនឹងរឿងមិនបានការរបស់មនុស្សមួយចំនួនទៅបានហើយ។

១១ - បើយើងចង់បញ្ចប់ភាពល្ងង់ខ្លៅរបស់ប្រជាជនយើង ត្រូវចាប់ផ្ដើមពីខ្លួនយើងទៅមុនសិន។

១២ - បើយើងឃ្លានរិះគន់ណាស់ រិះគន់អ្នកនយោបាយទៅ ព្រោះពួកគេមិនចេះខ្វល់ពីអ្នកណាទេ។

១៣ - កុំថាគេខូច យើងទេដែលមិនចេះឆ្ងល់។

១៤ - បើអ្វីក៏យើងមិនចេះឆ្ងល់ យើងសមនឹងត្រូវគេបោកហើយ។

១៥ - យើងត្រូវរៀនសួរខ្លួនឯងខ្លះ ទើបមានប្រយោជន៍។ រឿងមួយចំនួនដែលយើងត្រូវសួរមាន ៖ ហេតុអីក៏ខ្លួនយើងមិនមានលុយដូចគេ? តើអ្វីដែលគេនិយាយនេះពិតដែរឬទេ? ហេតុអីបានជាគេធ្វើបែបនេះ? តើយើងគួរចូលខ្លួនទៅពាក់ព័ន្ធដែរទេ? យើងរៀនសួរខ្លួនឯង ទើបមានកំណើត។

១៦ - ត្រូវចេះសំណួរគ្រប់រឿង តែសួរខ្លួនឯងបានហើយ មិនបាច់រំខានអ្នកដទៃទេ។

១៧ - ការរិះគន់ កើតពីចិត្តច្រណែនចំពោះអ្វីដែលអ្នកដទៃធ្វើបាន តែខ្លួនមិនអាចធ្វើបាន។

១៨ - ការពិតមួយ គឺយើងកំពុងត្រូវគេបោកជុំទិស។ អ្នកនយោបាយ ប្រព័ន្ធផ្សព្វផ្សាយ មនុស្សក្នុងសាសនា ប្រព័ន្ធអប់រំ និងអ្នកជុំវិញខ្លួន កំពុងតែបោកប្រាស់យើង។ យើងខ្លួនឯងក៏បោកខ្លួនឯងដែរ ដោយគិតថា អ្វីដែលយើងដឹងជាការពិត។

១៩ - បើសង្គមមួយមិនអនុញ្ញាតឱ្យរិះគន់ពាក្យកុហកក្នុងសាសនាទេ សង្គមនោះមានបញ្ហាមួយហើយ គឺអ្នកដឹកនាំយកសាសនាមកគ្រប់គ្រងខួរ

ក្បាលរបស់មនុស្ស។ ខ្មែរយើងក៏ដូចគ្នាដែរ ពេលជឿ គឺជឿងប់ដកខ្លួនមិនរួច។ ខ្មែរចូលចិត្តជឿ តែមិនចូលចិត្តយល់ទេ។

២០ - ដំណើងល្អ៖ មិនមែនជនជាតិយួនទាំងអស់ សុទ្ធតែឆ្លាតនោះទេ។ ដំណើងអាក្រក់៖ ប៉ុន្តែអ្នកដែលមិនឆ្លាតនោះ នៅស្រុកវៀតណាមឯណោះ។

២១ - មូលហេតុដែលយើងមិនទទួលស្គាល់ការពិតអ្វីមួយ មានតែពីរទេ គឺ ភ្លើ និងកំសាក។ មនុស្សភ្លើ មិនសំដៅលើមនុស្សដែលមិនចូលសាលាទេ តែសំដៅលើមនុស្សដែលមិនប្រើខួរក្បាល។ ចំណែកមនុស្សកំសាកវិញ គឺ ខ្លាចការពិតធ្វើឱ្យខ្លួនឯងមានបញ្ហា។

២២ - ខ្លួនឯងខ្លាចងាប់ទេ តែកុំមើលសម្តីក្នុងហ្វេសប៊ុក សុទ្ធតែដើម្បីជាតិ កុំខ្លាចស្លាប់។ តាមពិត ចង់រុញអ្នកដទៃឱ្យងាប់ជំនួសវាសោះ ហើយតាំង យកលេសមកយំស្រែក។ មនុស្សអីក៏អាក្រក់ម្លេះលោក!

២៣ - ម៉េចចេះតែឱ្យក្រមង៉ុយថាត្រូវបែបនេះ?

២៤ - កុំស្រលាញ់មនុស្សដែលងប់នឹងសម្ភារៈនិយម ព្រោះគេមិនអាច ស្រលាញ់យើងវិញទេ។

២៥ - ការយកមុខ កំពុងក្លាយជាវប្បធម៌ថ្មី ហើយវានឹងជ្រៀតចូលក្នុង មែកធាងអរិយធម៌របស់យើងម្តងបន្តិចៗ។

២៦ - យកមុខ ដើម្បីយកចិត្ត។

២៧ - នៅពេលយើងនិយាយពីរឿងវៀតណាម មានពាក្យពីរម៉ាត់ដែលយើងមិនត្រូវយកមកគិត និងយកមកប្រើ។ ពាក្យនោះគឺ "រើសអើងជាតិសាសន៍" និង "ជាតិនិយមជ្រុល"។ ខ្ញុំសង្ស័យតែពាក្យនេះ វៀតណាមជាអ្នកបង្កើត និងបណ្ដុះក្នុងគំនិតកូនខ្មែរផង ព្រោះបើពាក្យនេះត្រូវខ្មែរយើងយកមកគិតគ្រប់ពេល គោលបំណងគេនឹងឆាប់បានសម្រេច។ យើងមិនរើសអើងជាតិសាសន៍ទេ បើជាតិសាសន៍នោះគ្មានបំណងចង់គ្រប់គ្រងយើង ឬមិនធ្វើសកម្មភាពដែលមិនត្រឹមត្រូវ។ វៀតណាមក៏រើសអើងខ្មែរដែរ ព្រោះគេមានជាងយើង គេមានឋានៈធំជាងយើង និងមានសាច់សខ្ចីជាងខ្មែរយើង។ ជាតិនិយម ជាទស្សនៈប៉ុណ្ណោះ ដូច្នេះទោះបីជាយើងថែមពាក្យ "ជ្រុល" ចូលទៅក៏ដោយ ក៏វានៅតែជាំជាតិនិយមដែរ។ បើជាតិនិយមមិនជ្រុល គឺដូចសម័យមុនអ៊ីចឹង។ មួយចំហៀងថៃយក មួយចំហៀងយួនយក។

គិតដោយខ្លួនឯង!

២៨ - ចរិតអួត និងអាត្មានិយម កំពុងតែបំផ្លាញសង្គមនេះហើយ។

២៩ - គ្មានអ្នកណាអាចផ្លាស់ប្តូរចិត្តមនុស្សដែលសម្រេចថាធ្វើភ្លើតាមគេបានទេ។

៣០ - រឿងខ្លះយើងមិនអាចយល់បានទេ ព្រោះវាជ្រៅខ្លាំងពេក ហើយមានមនុស្សដែលនៅពីក្រោយ ដែលមិនចង់ឱ្យយើងយល់។

៣១ - គ្មានអ្នកណាចង់ឱ្យយើងឆ្លាតជាងគេនោះទេ។ យើងត្រូវតែចាំចំណុចនេះ។ បើគេមិនចង់ឱ្យយើងចេះគិត តើយើងត្រូវតែមិនចេះគិតតាមការចង់របស់គេមែនទេ?

៣២ - ភ្លើតាមគ្នាហ្នឹងហើយ ដែលបំផ្លាញប្រទេសខ្លួនឯងនោះ។ ភ្លើតាមគ្នាហ្នឹងហើយ ដែលតែរឿងក្តៅក្រហាយគ្រប់ពេល។ ភ្លើតាមគ្នាហ្នឹងហើយ ដែលធ្វើឱ្យក្មេងជំនាន់ក្រោយកើតមកភ្លើតាមដែរ។

៣៣ - ឃើញគេធ្វើល្អ យើងត្រូវចេះធ្វើល្អតាមគេ។ ឃើញគេធ្វើការច្រើន យើងត្រូវរៀនធ្វើការច្រើនតាមគេ។ តែបើឃើញគេធ្វើភ្លើ យើងត្រូវសួរខ្លួនឯងសិន។

៣៤ - "សេពគប់ជាមួយចោរនឹងក្លាយជាចោរសេពគប់ជាមួយបណ្ឌិតនឹងក្លាយជាបណ្ឌិត"។ នេះជាពាក្យចាស់បុរាណយើង តែឥលូវប្រហែលជាត្រូវប្តូរបន្តិចហើយ។ "សេពគប់ជាមួយចោរ នឹងក្លាយជាបណ្ឌិត សេពគប់ជាមួយបណ្ឌិត នឹងក្លាយជាខ្ញុំកញ្ជះចោរ"។

៣៥ - បើសិនជាយើងអាយុលើសពី១៨ឆ្នាំ វាល្មមដល់ពេលដែលយើងត្រូវរស់នៅដោយគោលការណ៍ខ្លួនឯងហើយ។ មិនថាសង្គម ឬអ្នកណាទេ គេមិនចង់ឱ្យយើងមានគោលការណ៍ខ្លួនឯងទេ ព្រោះវាពិបាកគ្រប់គ្រង និងពិបាកបោកយើងពេក។ ចាំខ្ញុំលើកឧទាហរណ៍ពីគោលការណ៍ផ្ទាល់ខ្លួនឱ្យស្តាប់ចុះ ក្រែងលោអាបង្កើតដោយខ្លួនឯងដែរ។

ទី១ រឿងអីក៏ដោយ បើខ្ញុំមិនចង់ធ្វើ ខ្ញុំមិនធ្វើដាច់ខាត ហើយនិយាយពាក្យអាក្រក់ដាក់អ្នកហៅខ្ញុំទៅធ្វើទៀត។

ទី២ ខ្ញុំមិនជឿពាក្យគ្រប់ម៉ាត់ដែលចេញពីមាត់អ្នកនយោបាយ កូនអុកនយោបាយ និងអ្នកដែលមិនយល់ពីនយោបាយតែប្រឹងធ្វើជាអ្នកវិភាគ។

ទី៣ ខ្ញុំមិនជឿសាសនាទេ តែរឿងមួយដែលខ្ញុំជឿពីសាសនា គឺពួកគេត្រូវការលុយមិនចេះចប់។

ទី៤ ខ្ញុំនឹងធ្វើឱ្យរឿងទាំងអស់ដែលខ្ញុំឆ្លងកាត់ ក្លាយជាសៀវភៅ។

ទី៥ ខ្ញុំមិនធ្វើជាមនុស្សកំសាកដាច់ខាត តែមិនលះបង់ខ្លួនឯងដើម្បីមហិច្ឆតា ឬភាពល្ងង់ខ្លៅរបស់អ្នកដទៃទេ។

នេះជាគោលការណ៍របស់ខ្ញុំ។ កុំជឿអ្វីដែលសង្គមនេះប្រាប់យើងពេកជួនកាលយើងអាចរស់នៅបានល្អជាងនេះក៏ថាបានដែរ ពេលដែលយើងធ្វើតាមខ្លួនឯង។

៣៦ - ព្រះក្នុងសាសនាអីក៏ស្រលាញ់មនុស្សដែរ តែទ្រង់ត្រូវការលុយដើម្បីទ្រទ្រង់សាសនារបស់ទ្រង់បន្តទៀត។ អ្នកដែលអត់លុយ ព្រះគ្រាន់តែស្រលាញ់ តែព្រះមិនត្រូវការទេ។ យើងមិនដឹងថាព្រះត្រូវការយើងឬអត់ទេ តែសាវ័ករបស់ព្រះថា មិនត្រូវការមនុស្សអត់លុយទេ។ បើមកបម្រើសាវ័កព្រះប្រហែលបាន។

ខ្ញុំមិនច្បាស់ថាព្រះត្រូវការមនុស្សអត់លុយឬអត់ទេ តែអ្វីដែលខ្ញុំដឹងគឺ ព្រះត្រូវការមនុស្សជួយជ្រោមជ្រែង។ បើអត់មានមនុស្ស ក៏អត់មានព្រះដែរ។

តែមនុស្សអាចរស់នៅដោយអត់ព្រះបាន ព្រោះរាល់ថ្ងៃយើងដែលរស់នៅ មិនមែនដោយសារព្រះមកចិញ្ចឹមយើងទេ គឺម៉ែឪយើងជាអ្នកប្រឹងចិញ្ចឹម យើង។

ដូច្នេះសំណួរគឺ តើព្រះជាអ្វី? ចម្លើយ គឺ ជាអីមិនសំខាន់ទេ សំខាន់មិនពាក់ព័ន្ធនឹងយើង។

៣៧ - ចរិតយើងយ៉ាងម៉េច រកបានមេដឹកនាំអ៊ីចឹង កុំទៅឆ្ងល់ច្រើន។

៣៨ - ល្ងង់ម្ភាក់ខ្លួនហើយ ជាតិយើងមិនមែនចេះដឹងជាងគេទេ។

៣៩ - យើងអានសៀវភៅដើម្បីជួយឱ្យខ្លួនយើងចេះដឹង និងអភិវឌ្ឍសង្គមរបស់យើងផង។

៤០ - អ្នកលោភលន់ទី១ ថាអ្នកលោភលន់ទី២ ជាមនុស្សអាក្រក់។ អ្នកលោភលន់ទី២ ចោទអ្នកលោភលន់ទី១ ជាមនុស្សលោភលន់។ រួចក៏មានអ្នកលោភលន់ទី៣ ចេញមកទៀត។ ចេញមកជាបន្តបន្ទាប់ តែសុទ្ធតែជាអ្នកលោភលន់ គ្រាន់តែវិធីផ្សាយពាណិជកម្ម និងម៉ាស់បិទមុខរបស់ពួកគេខុសគ្នាប៉ុណ្ណោះ។

ម៉ាសបិទមុខស្អាត អាចបាំងមុខអាក្រក់បានមួយឆាវ។ យូរទៅគេគង់តែនឹងដឹងថាមុខហ្នឹងវាអាក្រក់ទេ។

៤១ - មិនមែនគ្រប់យ៉ាងឱ្យតែស្របច្បាប់ សុទ្ធតែជារឿងត្រឹមត្រូវទាំងអស់ទេ។

៤២ - អ្នកខ្លះ សម្រេចចិត្តថាមិនប្រឹងរៀនទេ ហើយទៅធ្វើខ្ញុំគេ ដល់រួចមកបន្ទោសអ្នកដទៃទៅវិញ។

៤៣ - បើយើងទើសចិត្តនឹងអ្វីមួយ យើងមានវិធីពីរយ៉ាង គឺដើរចេញ ឬកែវាចេញ។ ក្រៅពីនេះ គ្មានបានផលទាំងអស់។

៤៤ - កុំមើលស្រាលភាពល្ងង់ខ្លៅរបស់មនុស្ស ព្រោះវាបានបំផ្លាញពិភពលោកច្រើនដងហើយ។

៤៥ - មិនថាយើងស្លៀកពាក់ស្អាតប៉ុណ្ណា មានឋានៈជាអ្វី ជិះឡានថ្លៃប៉ុណ្ណាទេ បើយើងជាមនុស្សកំសាក របស់ទាំងអស់នេះ ក៏មិនអាចបិទបាំងភាពកំសាករបស់យើងបានដែរ។ មនុស្សកំសាកនៅតែជាមនុស្សកំសាក មិនថាពេលវេលាផ្លាស់ប្តូរលឿនប៉ុណ្ណាទេ ក៏មិនអាចផ្លាស់ប្តូរឈ្មោះរបស់មនុស្សកំសាកបានដែរ។

មនុស្សកំសាក ជាមនុស្សលក់ក្បាល។ មនុស្សកំសាក ជាមនុស្សដែលមិនហ៊ានប្រឈមមុខនឹងការពិត។ មនុស្សកំសាក ជាមនុស្សដែលចេះតែទ្រជើងគេ។ មនុស្សកំសាក ជាមនុស្សដែលបានតែនិយាយ មិនព្រមធ្វើ។

៤៦ - រុញគេទាល់តែងាប់ ទើបមកធ្វើជាយំស្រែក ស្តាយស្រណោះ។ មិនត្រឹមតែកំសាកទេ អាក្រក់ទៀត។

៤៧ - អ្នកខ្លះកំសាកណាស់ បានត្រឹមតែរុញអ្នកដទៃឱ្យក្លាហានជំនួសខ្លួនប៉ុណ្ណោះ។

៤៨ - គ្មានអ្នកណាចាំឈ្មោះមនុស្សកំសាកទេ។

៤៩ - ហេតុអីមិនចង់ដឹងពីការពិត? ខ្លាច? មិនជឿ? ឬមិនដឹងថាយកទៅធ្វើអី? ការពិត មានប្រយោជន៍ណាស់។ វាធ្វើឱ្យយើងក្លាយជាមនុស្សចេះដឹងម្នាក់ ហើយលែងត្រូវគេបោកទៀត។

៥០ - ចាប់ដៃប្រជាជន និងថើបដី ជាពូជតែមួយ។

៥១ - ទ្រពង សម្ភារៈនិយម ស៊ីជោរ សុទ្ធតែបំផ្លាញសង្គមរបស់មនុស្ស និងបំផ្លាញមនុស្សខ្លួនឯងវិញដែរ។ដំបូងមនុស្សបំផ្លាញសង្គម ក្រោយមកសង្គម ក៏បំផ្លាញមនុស្សវិញ ដល់ចុងក្រោយ ទាំងមនុស្ស និងសង្គម សុទ្ធតែត្រូវបំផ្លាញ។

៥២ - មនុស្សធំពេញវ័យដែលមិនចេះគិត ជាមនុស្សដែលគ្រោះថ្នាក់បំផុត។

៥៣ - បើយើងជាជនជាតិយួន ក៏យើងមិនអាចបោះចោលគោលបំណងដែលជិតបានសម្រេចនេះដែរ។

៥៤ - ចាំអ្នកនយោបាយមកជួយដោះស្រាយបញ្ហាខ្លួនឯង ចាំខកហើយ។ ខ្លួនទីពឹងខ្លួន ។ ត្រូវចាំពាក្យចាស់បុរាណមួយនេះនៅក្នុងចិត្តជានិច្ច។ បើយើងចង់មានលុយចាយ ត្រូវធ្វើឱ្យខ្លួនឯងមានជំនាញ ហើយយកជំនាញនោះទៅរកលុយនៅខាងក្រៅ។ បើយើងចង់បានភាពស្មោះត្រង់ក្នុងសង្គម យើងត្រូវធ្វើខ្លួនជាមនុស្សស្មោះត្រង់ និងត្រូវបង្រៀនកូនខ្លួនឯងថាត្រូវស្មោះត្រង់យ៉ាងម៉េច។ បើយើងចង់ឈប់ឱ្យគេបោក យើងត្រូវរៀនឱ្យដឹងការពិតដោយខ្លួនឯង មិនបាច់ចាំអ្នកណាមកប្រាប់ទេ។

៥៥ - អ្នកណាប្រឹង អ្នកនោះបាន អ្នកណាចាំ ដេកចាំទៀតចុះ ។

៥៦ - ចេះអានសៀវភៅ តែមិនចេះគិត នៅតែមិនបានប្រយោជន៍ ។

៥៧ - មើលចរិតរបស់យើងសិន ចាំហាមាត់ស្រែក ។

៥៨ - ចរិតប្រជាជន បង្កើតបានជាចរិតអ្នកដឹកនាំ ។ បើប្រជាជនខ្ជិលគិត ពួកគេនឹងបានអ្នកដឹកនាំបោកមួយក្រុមមិនខាន ។

៥៩ - ជំនឿ គឺមនុស្សជាអ្នកបង្កើតទេ ដូច្នេះយើងចង់លុបចោលពេលណាក៏បានដែរ ។ បើសិនជាជំនឿណាមួយកំពុងបំផ្លាញយើង យើងត្រូវហ៊ានលុបជំនឿនោះចោល ។

៦០ - បើចាំដល់លទ្ធផលចេញមក ទើបយើងរៀនគិតឡើងវិញ វាហួសពេលបាត់ទៅហើយ ។

៦១ - ហេតុអី គេសរសើរបណ្ឌិតខ្លះ តែបែរជាជេរបណ្ឌិតផ្សេងទៀតទៅវិញ? តើបណ្ឌិតមានអីខុសគ្នា? បណ្ឌិតធ្វើមិនគិត ត្រូវតែគេជេរ ។

៦២ - ជំនាញខាងបន្ទោសគេនេះ ប្រើលែងបានផលហើយ ។ បើយើងចង់បានអី ចេញទៅធ្វើការដើម្បីរឿងនោះទៅ ។

៦៣ - ពេលដែលយើងកើតមកភ្លាម គេដាក់យើងទៅក្នុងប្រព័ន្ធជាច្រើនដែលមានស្រាប់ ហេតុនេះទើបយើងមិនអាចធ្វើអ្វីផ្សេងក្រៅពីរស់ក្នុងប្រព័ន្ធ ។ ប្រព័ន្ធទាំងនេះ ចងជើងយើងជាប់រហូតមក ។ បើយើងមិន

ព្យាយាមកាត់វាចេញទេ យើងនឹងរស់នៅបែបនេះរហូត។ វិធីមួយក្នុងចំណោមវិធីជាច្រើន គឺ ការចេះដឹង។

៦៤ - ទោះបីជាអ្នកវិភាគនិយាយត្រូវក៏ដោយ ទោះបីសម្តេចនិយាយពាក្យពិតក៏ដោយ ដែលថាប្រទេសខ្មែរបានដើរចេញពីវៀតណាមនោះ ក៏ខ្មែរមិនទាន់រួចខ្លួនដែរ។

ខ្មែរដើរចេញមែន តែវៀតណាមដើរចូល។ ជនជាតិវៀតណាមឆ្លាតជាងខ្មែរយើងឆ្ងាយណាស់ ឆ្លាតតាំងពីក្មេងមកម្ល៉េះ ព្រោះម៉ែឪគេ ចេះបង្រៀនកូន។ ទោះគ្មានវៀតណាមពីក្រៅមកទៀត ក៏វៀតណាមដែលមានក្នុងស្រុកអាចយកឈ្នះខ្មែរបានដែរ។ យើងខ្សោយជាងគេ មកពីខ្លួនយើងមិនចង់ខ្លាំងជាងគេ។ ជនជាតិយើងចង់ខ្លាំងតែមាត់ប៉ុណ្ណោះ ប៉ុន្តែមើលចរិតទៅដឹងហើយ។ ហើយអ្នកដែលចង់ខ្លាំងតែមាត់ហ្នឹង កំពុងត្រូវគេយកទៅធ្វើកូនអុកហើយ។

មានតែអ្នកដែលបោកខ្លួនឯងទេ ទើបគិតថា ខ្លួនឯងគ្មានចំណែកក្នុងការប្រជែងនឹងវៀតណាម ហើយទម្លាក់កំហុសឱ្យអ្នកនយោបាយ។ អ្នកនយោបាយត្រូវការប្រជាប្រិយភាព និងអំណាច គេមិនខ្វល់ពីរឿងយើងធ្វើជាកញ្ជះយួនទេ។ យ៉ាងច្រើនណាស់ បើសិនជាគេខ្វល់មែន គេដកយើងពីខ្ញុំយួន ទៅធ្វើខ្ញុំជនជាតិផ្សេងប៉ុណ្ណោះ។ ចង់ឈ្នះវៀតណាម ប្រឹងខ្លួនឯង។

**ខែកក្កដា ឆ្នាំ២០១៦**

៦៥ - ជាទូទៅ យើងប្រញាប់ជឿខ្លាំងពេក ហេតុនេះទើបគ្មានពេលគិតឱ្យ

បានច្បាស់លាស់។ មុនពេលយើងជឿអ្វីមួយ ត្រូវដកក្រោយមួយជំហានសិន ហើយត្រូវគិតថា តើនេះជាការពិត ឬជាការប្រឌិតរបស់អ្នកណាម្នាក់?

៦៦ - បំផ្លាញខ្លួនឯងដោយមិនដឹងខ្លួន គេហៅថាល្ងង់ ដឹងខ្លួនហើយនៅតែបំផ្លាញខ្លួនឯង គេហៅថាភ្លើ។

៦៧ - អួតចុះ អួតឡើង គេយកដីអស់។

៦៨ - ឱ្យគេទិញក្បាលបាន ទោះបីជារៀនដល់ស្រុកក្រៅណាក៏ដោយ នៅតែជាមនុស្សកំសាក។ មិនថាយើងមានលុយច្រើនប៉ុណ្ណា ចេញមុខតាមទូរទស្សន៍ច្រើនប៉ុណ្ណាក៏ដោយ បើយើងមិនហ៊ាននិយាយអ្វីដែលនៅក្នុងចិត្តយើងនៅតែជាមនុស្សកំសាក។ មិនថាយើងមានហេតុផល ឬលេសល្អយ៉ាងណាក៏ដោយ ឱ្យតែយើងមិនហ៊ានធ្វើការដើម្បីក្ដីស្រមៃខ្លួនឯង យើង

ជាមនុស្សកំសាកដដែល។ មនុស្សកំសាក ជាមនុស្សក្លាហានក្នុងរឿងអត់ប្រយោជន៍ តែរត់គេចពីរឿងរបស់ខ្លួនឯង។

៦៩ - មិនថាពេលណាក៏ដោយ មនុស្សកំសាក នៅតែជាមនុស្សកំសាក។

៧០ - ហេតុអីសុខចិត្តចំណាយពេល៣ខែរៀនភាសាកូរ៉េ ដើម្បីទៅធ្វើពលករ តែមិនព្រមចំណាយពេល៣ខែដើម្បីរៀនយកជំនាញក្នុងស្រុក?

ជំនាញអាយធី ក៏ត្រូវការពេលបីខែដែរ ហើយអាចប្រើការបានល្អទៀត។ ខ្ញុំយល់ហើយ ព្រោះទៅកូរ៉េ បានលុយច្រើនជាង តែអាយធីក៏រកលុយបានដែរ ហើយមិនចាំបាច់ទៅឆ្ងាយពិបាកទៀត។ ការងារណាក៏មានតម្លៃ តែនៅពេលគេ គិតដល់មុខមាត់ប្រទេស គេចាំបាច់ត្រូវចែកប្រភេទការងារ

ហើយ។ ការងារដែលយើងធ្វើ ក៏បង្ហាញពីមុខមាត់របស់ប្រទេសយើងដែរ មិនមែនទាល់តែទៅចូលរួមប្រកួតយកពានរង្វាន់អ្វីមួយទេ។

ទុកថាខ្ញុំភ្លើចុះ។ ខ្ញុំសុខចិត្តធ្វើខ្ញុំគេនៅក្នុងស្រុក ក៏មិនទៅក្រៅធ្វើខ្ញុំគេដែរ។

៧១ -បើចាំអ្នកដទៃ មកជួយយើងដដែល ជួយខ្លួនឯងល្អជាង។

៧២ - ហេតុអីបានជា លោកតា ក្រមង៉ុយ នៅតែនិយាយត្រូវពីចំណុចនេះ? ម៉េចបានជាយើងនៅតែរងកម្ម? រាប់ឆ្នាំមកហើយ តាំងពីជំនាន់បារាំង នៅតែរងកម្មទៀត អ៊ីចឹងបានន័យថា ខ្មែរអត់មានផ្លាស់ប្ដូរទេ? ប្ដូរតែសម្បកក្រៅប៉ុណ្ណោះ។ ដូច iPhone 5 ឡើងសេរី iPhone 6 mini ។

៧៣ - អ្នកខ្លះកុហកខ្លួនឯងថា ស្រលាញ់ជាតិ។

៧៤ - បើឈឺចេះតែទ្រាំបែបនេះ ប្រាកដជាត្រូវឈឺរហូតហើយ។ អ្នកខ្លះធ្វើការឱ្យចិន ឱ្យយួន ត្រូវគេមើលងាយគ្រប់សព្វបែបយ៉ាង តែមិនប្រឹងរៀនអ្វីផ្សេងទេ។ សុខចិត្តបណ្ដោយខ្លួនឱ្យមិនចេះអ្វីទាំងអស់ ប្រើកម្លាំងធ្វើការ ក្រោមទឹកមាត់ដែលខ្ជាយចេញពីមាត់ចិនរាល់ថ្ងៃ។ នេះគេហៅថាឈឺតែមិនចេះរើខ្លួន។

៧៥ - អ្នកណាក៏ចេះឈឺដែរ ពេលត្រូវគេមើលងាយ តែវាខុសគ្នាត្រង់ថាតើក្រៅពីឈឺហើយ យើងធ្វើអ្វីបន្តទៀត?

៧៦ - ជួយខ្លួនឯងឱ្យបានសិន ចាំចង់ជួយជាតិ។

៧៧ - លោភពេក បំផ្លាញតែជាតិឯង។

៧៨ - ការជោរតាមគ្នានេះ ជួយអីមិនបានទេ ហើយដោះស្រាយអ្វីក៏មិនចេញដែរ។ ពួកអ្នកមានលុយ និងអ្នកមានអំណាច គេដេកបន់ឱ្យតែមនុស្សជោរតាមគ្នាហ្នឹងហើយ នឹងអាលគេកើបលុយ កើបអំណាចឱ្យអស់ចិត្ត។

៧៩ - ខ្ញុំឆ្ងល់ណាស់ តើអ្នកមាន គេនឹងជួយអ្នកក្រ ឬក៏អ្នកមានគ្នាគេ? ខ្ញុំឆ្ងល់ទៀតថា អ្នកក្រដែលឡើងធំ នឹងជួយអ្នកក្រ ឬជួយអ្នកមានដែលបានផ្តល់តំណែងឱ្យ?

៨០ - ឆ្កួត និងភ្ញាក់ខ្លួន មិនដូចគ្នាទេ។ ពេលខ្លះយើងមិនមែនឆ្កួតទេ យើងគ្រាន់តែភ្ញាក់ខ្លួនប៉ុណ្ណោះ។

៨១ - ប្រយ័ត្នខ្លួនផង ពេលដែលអ្នកក្រៅហៅយើងថាបងប្អូន។

ថៃ និងវៀតណាម ក៏ធ្លាប់ហៅខ្មែរថាបងប្អូនដែរតាំងពីបុរាណមក។ អ្នកសិល្បៈ និងអ្នកនយោបាយ ក៏ហៅយើងថាបងប្អូនដែរ។ ប្រយ័ត្នបងប្អូនដើម្បីប្រយោជន៍។

៨២ - នៅពេលដែលការទ្រពងក្លាយជាអាជីពពេញនិយមមួយ តើស្រុកខ្មែរនឹងទៅជាយ៉ាងណា?

៨៣ - កុំរស់នៅដោយពឹងលើការទ្រពង។

៨៤ - មានលុយច្រើន តែរកថ្លៃមិនឃើញ។

៨៥ - អ្នកខ្លះជិះឡានថ្លៃណាស់ តែគួរឱ្យស្តាយ ថ្លៃតែឡាន។

៨៦ - មានមោទនភាពពេក ក៏បែរជាគិតថា ជាតិសាសន៍ដទៃល្ងង់ជាងខ្លួន

ឯងទៅវិញ។

៨៧ - ចង់ដឹងសង្គមមួយរីកចម្រើនឬអត់ មើលតែចរិតមនុស្សក្នុងសង្គម នោះទៅ ដឹងហើយ។ មិនបាច់ចំណាយពេលអានស្ថិតិអីនោះទេ។

៨៨ - កើតមកនឹងគេដែរ តែកំសាកមិនហ៊ានទទួលការពិត តើសមទេ?

៨៩ - ការមិនដឹងពីការពិត មិនធ្វើឱ្យយើងក្លាយជាមនុស្សភ្លើទេ តែការមិនចង់ដឹងការពិត ទើបជាចរិតរបស់មនុស្សភ្លើ។

៩០ - យើងនឹងអន់ជាងគេមួយជីវិត បើយើងនៅតែប្រកាន់គំនិតថា យើងចេះអស់ហើយ ឬយើងធ្លាប់ខ្លាំងជាងគេហើយ។

៩១ - កុំខាតទឹកមាត់ ជាមួយមនុស្សដែលគ្មានខួរ ឬមានខួរ តែមិនគិត។

៩២ - បើចង់ចេះ ត្រូវចំណាយលុយ ពេលវេលា និងកម្លាំងដើម្បីរៀន។ បើចង់មានបាន ត្រូវចំណាយកម្លាំងខួរក្បាលដើម្បីគិតវិធីសាស្ត្ររកលុយ។ បើចង់ក្លាយជាមនុស្សល្អ ត្រូវចំណាយកម្លាំងចិត្តដើម្បីគ្រប់គ្រងចិត្តមិនល្អរបស់ខ្លួនឯង។

៩៣ - ជនជាតិគេ មកស្រុកយើង ធ្វើជាមេ ជនជាតិយើង ទៅស្រុកគេ ធ្វើជាខ្ញុំ។

៩៤ - យើងអាចយកការស្លាប់របស់ បណ្ឌិត កែមឡី មកបំបាក់ទឹកចិត្តខ្លួនឯងក៏បាន ឬយកមកដាស់ស្មារតីខ្លួនឯងក៏បាន។ នេះជាជម្រើសផ្ទាល់ខ្លួន។ រើសឱ្យហើយទៅ ទាន់នៅអាចរើសបាន។

៩៥ - កុំឱ្យគេស្លាប់ ដោយសារតែភាពល្ងង់របស់យើង។ កុំឱ្យគេស្លាប់ ដោយសារតែយើងមិនចង់ចេះដឹង។ កុំឱ្យគេស្លាប់ ដោយសារតែយើងមិនបានទទួលការពិត និងកុំឱ្យស្លាប់ ដើម្បីឱ្យយើងបាន Share រូបភាពកាន់ទុកលើហ្វេសប៊ុក។

៩៦ - គ្រប់ប្រព័ន្ធទាំងអស់ បង្កើតឡើងដើម្បីការពារម្ចាស់ប្រព័ន្ធ។ ប្រព័ន្ធទាំងនោះអាចផ្តល់ប្រយោជន៍ដល់អ្នកដទៃដែរ តែត្រូវប្រាកដថា អ្នកទាំងនោះមិនធ្វើឱ្យប៉ះពាល់ដល់ប្រយោជន៍ម្ចាស់ប្រព័ន្ធជាដាច់ខាត។ នៅពេលដែលយើងសម្រេចចិត្តថាចូល ឬត្រូវគេបង្ខំឱ្យចូលក្នុងប្រព័ន្ធ យើងត្រូវដើរតាមគេហើយ។

ខ្ញុំឧទាហរណ៍ ហ្វេសប៊ុកមិនអនុញ្ញាតឱ្យយើង ផុសរូបភាពស្រាតទេ។ យើងអាចផុសបាន តែនៅពេលដែលគេដឹង គេនឹងបិទឈ្មោះយើងមិនខាន។ បើយើងផុសរូបបែបនេះ ប្រព័ន្ធរបស់គេនឹងត្រូវខូចឈ្មោះដោយសារយើង ហើយម្ចាស់ប្រព័ន្ធ ក៏ត្រូវគេនិយាយដើមដែរ ។ ហ្វេសប៊ុកជា ប្រព័ន្ធមួយ។ យើងមិនអាចគេចពីប្រព័ន្ធបានទាំងអស់ទេ តែយើងអាចគេចបានមួយចំនួន ដូច្នេះសូមគិត មុននឹងចូលប្រព័ន្ធណាមួយ។

៩៧ - តើអ្នកទាំងអស់គ្នាជឿទេថា ការស្លាប់របស់ បណ្ឌិត កែមឡី ក៏មានទាក់ទងនឹងយើងទាំងអស់គ្នាដែរ?

គាត់និយាយរិះគន់អ្នកនយោបាយមែន តែគោលបំណងមិនមែនឱ្យតែអ្នកនយោបាយស្តាប់នោះទេ។ គាត់ក៏ដឹងថា អ្នកនយោបាយគេមានរបៀបគេធ្វើការផ្សេងពីគាត់ ហេតុនេះគេមិនស្តាប់គាត់ទេ។ ដូច្នេះតើគាត់និយាយ

ឱ្យអ្នកណា។

ប្រហែលជានិយាយឱ្យយើងគ្រប់គ្នាស្តាប់ ព្រោះគាត់គិតថា បើកែអ្នកនយោបាយឥលូវមិនបាន អ៊ុំចឹងមានតែកែអ្នកនយោបាយអនាគតវិញ។ អ្នកណាមើលដឹងថា ខ្លួនឯងនឹងទៅជាអីនៅថ្ងៃក្រោយនោះ។

ដោយសារតែយើងគ្រប់គ្នាល្ងង់ ហើយត្រចៀកស ទើបគាត់ត្រូវនិយាយឱ្យច្រើនបន្តិច និយាយឱ្យចំបន្តិច។ ការនិយាយបែបនេះ ប៉ះពាល់គេខ្លាំងណាស់ ទើបគាត់មានរឿងបែបនេះទៅ។ បើយើងគ្រប់គ្នា ចេះស្វែងយល់ទទួលការពិត និងចេះប្រើខួរក្បាលគិតឱ្យបានច្រើនបន្តិច គាត់ក៏មិនហត់មាត់និយាយដែរខ្ញុំប្រហែលទេ ព្រោះខ្ញុំមិនចេះវិភាគ តែខ្ញុំមានអារម្មណ៍បែបនេះពិតមែន។ បើខ្មែរចេះដឹង និងចេះគិត តើយើងត្រូវការឱ្យអ្នកវិភាគមកប្រថុយជីវិតដើម្បីនិយាយរឿងក្នុងស្រុកដែរទេ?

៩៨ - ខ្ញុំចង់ដឹងណាស់ ថាវៀតណាមគេប្រដៅកូនចៅគេរបៀបម៉េច។ ចាំសាកស្មានបន្តិចសិន ក្រែងលោវាត្រូវចំណុច។

៩៩ - វៀតណាមខុសពីខ្មែរយើង។ នៅពេលបានប្រយោជន៍គេនឹងប្រឹងប្រមូលយក តែគេមិនដែលធ្វើអីប៉ះពាល់ដល់ជាតិគេទេ។ គេមិនគាំទ្រសាសន៍ផ្សេងមកគ្រប់គ្រងប្រជាជនគេទេ។ គេប្រឹងយកងាប់យករស់ ឱ្យបានធ្វើជាមេលើសាសន៍ផ្សេង ព្រោះគេមិនចង់ឱ្យជនជាតិគេនៅពីក្រោមគេ។

ចំណែកខ្មែរវិញ ផ្ទុយពីនេះ។ មិនអីទេ ឱ្យតែបានលុយ ហើយណាមួយ

វៀតណាមក៏ល្អនឹងយើងដែរ។ គេល្អនឹងយើង ព្រោះយើងមានប្រយោជន៍ឱ្យគេ។ បើមិនជឿ ចាំមើលពេលគេលែងត្រូវការយើងទៅ ដឹងគ្នាហើយ។

កុំភ្លេច តែអុង។

១០០ - កាលពីអាទិត្យមុនមានគេសួរថា តើធ្វើយ៉ាងម៉េចទើបអាចយកឈ្នះវៀតណាមបាន? ខ្ញុំអត់ដឹងទេ តែមានរឿងខ្លះបើសិនជាយើងឈប់ធ្វើ ឬកាត់បន្ថយឱ្យបានច្រើន យើងប្រហែលជាអាចមានសង្ឃឹមឈ្នះបានខ្លះ។

វាអត់មានទាក់ទងនឹងរឿងសង្គ្រាម ឬរឿងកាប់សម្លាប់គ្នាទេ តែវាទាក់ទងនឹងអ្វីដែលយើងធ្វើរាល់ថ្ងៃនេះ។

អានហើយ គិតផង កុំអានចោល។

- យើងមិនអាចឈ្នះវៀតណាមបានទេ បើខ្មែរតាំងខ្លួនជាអ្នកចម្បាំងក្រុងអង្គរគ្រប់ពេលបែបនេះ។ ឈ្លោះគ្រប់រឿង ឈ្លោះគ្រប់កន្លែង តែឈ្លោះអត់ប្រយោជន៍ប៉ុណ្ណោះ។

- យើងមិនអាចឈ្នះវៀតណាមបានទេ បើយើងចេះត្រឹមតែស្អប់យួននោះ។

- យើងមិនអាចឈ្នះវៀតណាមបានទេ បើយើងចេះតែធ្វើការឱ្យក្រុមហ៊ុនរបស់វៀតណាមនោះ។

- យើងមិនអាចឈ្នះវៀតណាមបានទេ បើយើងចេះតែនិយាយអាក្រក់ពីវៀតណាមនោះ។

- យើងមិនអាចឈ្នះវៀតណាមបានទេ បើយើងនៅតែពឹងលើអ្នកនយោបាយ និងជឿលើពាក្យឃោសនាទាំងនោះ។

- យើងមិនអាចឈ្នះវៀតណាមបានទេ បើខ្មែរនៅតែល្ងង់ និងជោរតាមគ្នាគ្រប់ពេលនោះ។

- យើងមិនអាចឈ្នះវៀតណាមបានទេ បើខ្មែរនៅតែមានអំណួត និងឆ្កួតតាមរូបភាពនិយម។

- យើងមិនអាចឈ្នះវៀតណាមបានទេ បើខ្មែរនៅតែជឿលើជំនឿអត់មានហេតុផល និងបណ្តោយខ្លួនតាមយថាកម្ម។

- យើងមិនអាចឈ្នះវៀតណាមបានទេ បើខ្មែរមានគំនិតស្នេហាជាតិតែមាត់។

- យើងមិនអាចឈ្នះវៀតណាមបានទេ បើខ្មែរគ្មានគំនិតធ្វើមេ ដូចវៀតណាមនោះ។

- យើងមិនអាចឈ្នះវៀតណាមបានទេ បើខ្មែរមិនចេះជួយខ្លួនឯង និងរង់ចាំជំនួយពីក្រៅរហូតនោះ។

-យើងមិនអាចឈ្នះវៀតណាមបានទេ បើខ្មែរខ្លាំងបានតែជាមួយខ្មែរគ្នាឯង ហើយខ្លាចគេឡើងរួញនោះ។

-យើងមិនអាចឈ្នះវៀតណាមបានទេ បើខ្មែរនិយាយរកតែឈ្លោះគ្នារហូតនោះ។

- យើងមិនអាចឈ្នះវៀតណាមបានទេ បើខ្មែរចេះតែកុហកខ្លួនឯង និងគិតថាខ្លួនឯងខ្លាំងរហូតនោះ។

- យើងមិនអាចឈ្នះវៀតណាមបានទេ បើខ្មែរស្រលាញ់លុយ ជាងប្រទេសរបស់ខ្លួន។

- យើងមិនអាចឈ្នះវៀតណាមបានទេ បើខ្មែរមិនចេះអានសៀវភៅ ហើយគិតថាខ្លួនឯងចេះអស់ហើយនោះ។

-យើងមិនអាចឈ្នះវៀតណាមបានទេ បើខ្មែរចេះតែរិះគន់អ្នកដែលខំធ្វើ ហើយខ្លួនឯងដេកអេះពង។

-យើងមិនអាចឈ្នះវៀតណាមបានទេ បើខ្មែរនៅតែជឿថា ឱ្យតែស្របច្បាប់ សុទ្ធតែជារឿងត្រឹមត្រូវទាំងអស់នោះ។

-យើងមិនអាចឈ្នះវៀតណាមបានទេ បើខ្មែរមានខួរដែរ តែទុកចោល។

-យើងមិនអាចឈ្នះវៀតណាមបានទេ បើខ្មែរជឿលើអ្នកដឹកនាំជ្រុលពេក ហើយមិនជឿលើសមត្ថភាពខ្លួនឯង។

១០១ - ហេតុអ្វីបានជាវៀតណាមឆ្លាតជាងខ្មែរ?

- វៀតណាមដឹងថា ចំណេះដឹងជាអាវុធទីមួយ។

- វៀតណាមឈាមរាវមុនខ្មែរ តែឆាប់កកជាងខ្មែរ។

- វៀតណាមដឹងថាក្រៅពីចំណេះដឹងហើយ លុយជាអាវុធដ៏អស្ចារ្យមួយទៀត។

- វៀតណាមិនភ្លេចទេពីអំណាច ព្រោះដើម្បីសង្កត់អ្នកនៅខាងក្រោម ។

- វៀតណាមមើលប្រយោជន៍ឆ្ងាយ គឺប្រយោជន៍ដែលមេដឹកនាំរបស់គេបានកំណត់ទុក ។

- វៀតណាមដឹងថា ខ្មែរមិនទទួលស្គាល់ថាខ្លួនល្ងង់ទេ ហេតុនេះគេត្រូវប្រឹងឱ្យដល់មុនពេលដែលខ្មែរភ្ញាក់ខ្លួន ។

ឆ្លាត ឬមិនឆ្លាត យើងអាចមើលដឹងដោយខ្លួនឯងហើយ ។ គ្រាន់តែយើងមិនហ៊ានទទួល ព្រោះគិតថាវាជារឿងអាម៉ាសប៉ុណ្ណោះ ។

១០២ - ខ្ញុំសូមនិយាយបន្តិច ។ ការលួចរបស់គេមកផុសបែបនេះ គេមិនហៅថាការចែករំលែកទេ ។ ការចែករំលែក ចេញពីចិត្ត ចេញពីការខំប្រឹងខ្លួនឯង ។ បើចាំតែយកផលរបស់អ្នកដទៃមកផុសអួតគេបែបនេះ គេហៅថា ចោរ ។

បើអ៊ីចឹង ពេលវៀតណាមលួចយកដីខ្មែរ យើងម៉េចមិននាំគ្នាហៅថា ចែករំលែកដែរទៅ ព្រោះវាក៏យកទៅចែកឱ្យជនជាតិវារស់នៅដែរ ។ វាមានយកទៅទុកឯណា ។

ហើយពេលចិនលួចស៊ីកម្លាំងពលកម្មរបស់យើង យើងមិនហៅថាចែករំលែកដែរទៅ ព្រោះពួកចិនយកអ្វីដែលយើងធ្វើទៅចែកគ្នាវាដែរតើ ។

កុំដោយសារតែប្រយោជន៍ខ្លួនឯង ហើយធ្វើឯងមកនិយាយ "ខ្មែរអើយខ្មែរគ្រាន់តែចែករំលែកមិនបានដែរ " ។ ចេះខ្មាសខ្លួនឯងខ្លះ ទើបគេហៅថាមនុស្ស ។

១០៣ - កុំរស់នៅដោយហ៊ុំព័ទ្ធខ្លួនឯងជាមួយនឹងការបោកប្រាស់ ។

១០៤ - ចេះច្បាប់ហ្នឹងហើយ ធ្វើចោរស្រួល ។

១០៥ - ឥលូវនេះ ផេកដែលលួចសៀវភៅខ្ញុំ និងសៀវភៅជាច្រើនទៀត យកទៅ Post នោះ វាស្គាល់ពាក្យសិទ្ធិអ្នកនិពន្ធហើយ ។

វាបានបញ្ជាក់ថា វាពុំបានធ្វើអាជីវកម្មដើម្បីប្រយោជន៍ផ្ទាល់ខ្លួនវាឡើយ ។ វាធ្វើបានមនុស្សចុច Like ផេកវារាប់សែននាក់ហើយ វាថាអត់បានប្រយោជន៍ទៀត? អ៊ីចឹងផេកអ្នកនិពន្ធសៀវភៅដែលវាលួចយកមកនោះ តើបានអីខ្លះ? គ្រាន់តែឈ្មោះក៏គេសរសេរខុសដែរ ។ មិនមែនទាល់តែបានលុយ ទើបហៅថា ប្រយោជន៍ផ្ទាល់ខ្លួនទេ ។

វាឈប់លួចគេអ៊ីចឹង ជារឿងល្អហើយ ។ ប៉ុន្តែវាបានធ្វើឱ្យប្រជាជនខ្មែរផ្សេងទៀត មើលងាយស្នាដៃអ្នកនិពន្ធ ដោយគិតថា e-Book គ្រាន់តែជា file ដែលអាចដោនឡូដបានដោយសេរី ។ ចុចអាន comment ទៅនឹងដឹងហើយថាកូនខ្មែរឱ្យតម្លៃអ្នកនិពន្ធ ឬគិតពីប្រយោជន៍ខ្លួនឯង?

អាផេកនេះ បើយើងយកទៅប្រៀបនឹងពួកអាណានិគមបារាំង ត្រូវគ្នាតែម្តង ។ ទម្រាំតែវាប្រកាសថាឈប់ ប្រជាជនខ្មែរបាក់ស្បាតអស់ អ្នកស្នេហាជាតិស្លាប់គរជើង ហើយអស់ដីកោះមួយដុំធំទៀត ។ វាឈប់មែន តែវាបានបំផ្លាញផ្លូវដើរអស់ហើយ ។

នៅស្រុកខ្មែរ មានមនុស្សដូចវាច្រើនណាស់ ។ បំផ្លាញហើយ ទើបធ្វើជាភ្ញាក់ខ្លួន ។ បានប្រយោជន៍ទេ? បានតែមុខមាត់វាហ្នឹង ។

១០៦ - ឥលូវ ខ្ញុំច្បាស់មែនទែនហើយ ថាស្រុកខ្មែរ សម្បូរមនុស្សកំសាក ក្នុងចិត្ត។ ពួកគេមិនហ៊ានទទួលការពិតទេ។ គ្រាន់តែលឺការពិតភ្លាម ក៏ស្រែកជេរ និងរិះគន់អ្នកដែលអ្នកនិយាយការពិតភ្លាម។

Global Witness គេបញ្ចេញទិន្នន័យឱ្យដឹង ក៏មានអ្នកជេរថា គេហ្នឹងច្រណែនគ្រួសារសម្តេច ចង់វាយប្រហារសម្តេចទៅវិញ។ ខ្ញុំឆ្ងល់ ភ្នែកមានរាល់ថ្ងៃហ្នឹងអត់ចេះមើលទេអី។ បែបនាំគ្នា គិតថាសម្តេចក្រហើយមើលទៅ។

អ្នកខ្លះគេចេះដើររកការពិត ចង់ដឹងរឿងឱ្យច្បាស់។ អ្នកខ្លះកំសាកពីកំណើត រត់គេចពីការពិត និងវាយប្រហារការពិតវិញទៀត។ មនុស្សបែបនេះហើយ ដែលចូលរួមទាក់ជើងស្រុកយើងមិនឱ្យរីកចម្រើន។

១០៧ - ឥលូវនេះ ផេកដែលលួចសៀវភៅខ្ញុំ និងសៀវភៅជាច្រើនទៀតយកទៅ Post នោះ វាស្គាល់ពាក្យសិទ្ធិអ្នកនិពន្ធហើយ។

វាបានបញ្ជាក់ថា វាពុំបានធ្វើអាជីវកម្មដើម្បីប្រយោជន៍ផ្ទាល់ខ្លួនវាឡើយ។ វាធ្វើបានមនុស្សចុច Like ផេកវារាប់សែននាក់ហើយ វាថាអត់បានប្រយោជន៍ទៀត? អ៊ីចឹងផេកអ្នកនិពន្ធសៀវភៅដែលវាលួចយកមកនោះតើបានអីខ្លះ? គ្រាន់តែឈ្មោះក៏គេសរសេរខុសដែរ។ មិនមែនទាល់តែបានលុយ ទើបហៅថា ប្រយោជន៍ផ្ទាល់ខ្លួនទេ។

វាឈប់លួចគេអ៊ីចឹង ជារឿងល្អហើយ។ ប៉ុន្តែវាបានធ្វើឱ្យប្រជាជនខ្មែរផ្សេងទៀត មើលងាយស្នាដៃអ្នកនិពន្ធ ដោយគិតថា e-Book គ្រាន់តែជា

file ដែលអាចដោនឡូដបានដោយសេរី។ ចុចអាន comment ទៅនឹងដឹង ហើយថាកូនខ្មែរឱ្យតម្លៃអ្នកនិពន្ធ ឬគិតពីប្រយោជន៍ខ្លួនឯង?

អាផេកនេះ បើយើងយកទៅប្រៀបនឹងពួកអាណានិគមបារាំង ត្រូវគ្នាតែម្តង។ ទម្រាំតែវាប្រកាសថាឈប់ ប្រជាជនខ្មែរបាក់ស្បាតអស់ អ្នកស្នេហាជាតិស្លាប់គរជើង ហើយអស់ដីកោះមួយដុំធំទៀត។ វាឈប់មែន តែវាបានបំផ្លាញផ្លូវដើរអស់ហើយ។

នៅស្រុកខ្មែរ មានមនុស្សដូចវាច្រើនណាស់។ បំផ្លាញហើយ ទើបធ្វើជាភ្ញាក់ខ្លួន។ បានប្រយោជន៍ទេ? បានតែមុខមាត់វាហ្នឹង។

១០៨ - នយោបាយ ជាសិល្បៈនៃការដឹកនាំប្រទេស ហេតុនេះនយោបាយមិនដែលនិយាយកុហកទេ។ ប៉ុន្តែអ្នកនយោបាយ ជាអ្នកដែលទាញប្រយោជន៍ពីនយោបាយប៉ុណ្ណោះ ហេតុនេះពួកគេត្រូវតែនិយាយកុហក។ បើប្រាប់គេតាមត្រង់ តើអ្នកណាភ្លើឱ្យយកប្រយោជន៍បាននោះ?

អ្នកនយោបាយណាក៏និយាយកុហកដែរ គ្រាន់តែតិច ឬច្រើន តាមសមត្ថភាពដែលអាចឡើងនិយាយបានប៉ុណ្ណោះ។

១០៩ - ភាពមិនស្មោះត្រង់ ជាគោលការណ៍របស់អ្នកនយោបាយ។

១១០ - មនុស្សម្នាក់អាចចំណាយពេលរាប់ម៉ោង អានពតិមានផ្សេងៗនៅលើអ៊ីនធឺណេត តែមិនអាចផ្លាស់ប្តូរអ្វីបានទាំងអស់ សូម្បីតែខ្លួនឯង។

១១១ - កុំគិតថាខ្លួនឯងឆ្លាត ដោយសារតែបានស្តាប់អ្នកនយោបាយនិយាយ ឬអ្នកវិភាគនិយាយឱ្យសោះ។ បើយើងឆ្លាតមែន យើងមិន

ចំណោយពេលលើរឿងទាំងនេះទេ ជាពិសេស នៅពេលដែលយើងនៅមិនទាន់ជួយខ្លួនឯងរួច។

១១២ - បើចាំតែថាតាមអ្វីដែលអ្នកដទៃគិត មួយជីវិតនេះ យើងនឹងបម្រើគំនិតអ្នកដទៃជានិច្ច។

១១៣ - ស្នេហាជាតិ មិនមែនស្នេហាបក្សទេវើយ។ បក្ស មិនមែនជាជាតិទេ។ បក្សដួលប៉ុន្មានក៏គ្មានបញ្ហាដែរ តែបើជាតិដួល ស្អីក៏ចប់ដែរ។

១១៤ - សំណេរ ឬសៀវភៅដែលយើងអាន នឹងជះឥទ្ធិពលដល់យើង។ បើថ្ងៃនេះ វាមិនទាន់ជះទេ នៅថ្ងៃណាមួយក៏វានឹងជះមកដែរ។ ហេតុនេះត្រូវប្រយ័ត្នអ្វីដែលយើង។

បើនាំគ្នាអានតែរឿងលើកជើង យើងនឹងក្លាយជាមនុស្សលើកជើង។ បើមិនជឿសាកចូលទៅផេកសម្តេច ហើយអាន Comment រាល់ថ្ងៃទៅ។ មិនយូរទេ យើងនឹងចូលទៅ Comment ដូចគេដែរមិនខាន។

១១៥ - កុំអានអ្វីដែលសរសេរលើកជើង ព្រោះថ្ងៃណាមួយវានឹងធ្វើឱ្យយើងក្លាយជាមនុស្សលើកជើងដែរ។

១១៦ - ខ្ញុំនិយាយពាក្យស្មោះត្រង់មួយឱ្យដឹងចុះ។ បើអ្នកណាចូលមក comment ភ្លើនៅលើផេកនេះ ខ្ញុំ ban ចោលហើយ។ ខ្ញុំមិនចូលចិត្តមនុស្សភ្លើទេ ព្រោះពួកនេះគ្រោះថ្នាក់ ហើយធ្វើឱ្យយើងខាតពេលទៀត។

ខ្ញុំនិយាយពាក្យស្មោះត្រង់មួយទៀត។ ខ្ញុំគិតថា ស្រុកខ្មែរ រីកចម្រើនក្លែងក្លាយទេ ឬរីកចម្រើនតែម្តុំគ្នាគេ។

១១៧ - អ្នកដែលខឹង នៅពេលយើងនិយាយការពិត គឺជាអ្នកដែលនិយាយកុហក ឬមនុស្សដែលមិនចូលចិត្តការពិត។

១១៨- ការពិត មិនពិរោះស្តាប់ទេ ជួនកាលដឹងហើយ អាចធ្វើឱ្យយើងឈឺចាប់ ឬខឹងក៏ថាបាន។ ដូច្នេះបើយើងកំសាកទេ រស់នៅជាមួយរឿងមិនពិតដល់ចាស់ស្លាប់ទៅ ហើយកុំស្រែកថា ចង់ដឹងការពិតឱ្យសោះ។

ចង់ទទួលការពិត ត្រូវមានចិត្តក្លាហានជាមុនសិន។

១១៩ - ឱ្យតែមេធំសម្តែងហើយ អាតូចតាចខាងក្រោម ក៏ធ្វើតាមដែរ។ ថ្ងៃណាមួយស្រុកខ្មែរ នឹងបានពានខាងសម្តែងគ្រប់គ្នាមិនខាន។ ខ្ញុំចង់បានពានជាអ្នកសរសេរ អារឿងសម្តែងធ្វើមិនឈ្នះគេទេ។

១២០ - ការសម្តែងកំពុងតែពេញនិយម ព្រោះសង្គមកំពុងតែឱ្យតម្លៃ អ្នកដែលចេះសម្តែង។

១២១ - ការពិតដែលគេប្រឌិត មានគ្រប់ទិសទី។ សូមប្រយ័ត្ន!

១២២ - ភាគច្រើនអ្នកដែលចាញ់បោកគេ សុទ្ធតែជួយគេឱ្យបោកខ្លួនឯងបានសម្រេច។ បើយើងមិនជឿ តើអ្នកណាមកបោកយើងបាន? កុំបោកខ្លួនឯង ឱ្យអ្នកដទៃបោកបាន។

១២៣ - ខ្ញុំស្គាល់ជនជាតិវៀតណាមច្រើនណាស់។ ខ្ញុំជឿថា អ្នកទាំងអស់គ្នានឹងគិតថាខ្ញុំមិនចេះលើកតម្កើងជាតិខ្លួនឯង នៅពេលខ្ញុំនិយាយថា ជនជាតិវៀតណាមឆ្លាតជាងជាតិខ្មែរ។

ខ្ញុំមិនមែននិយាយពីចំណេះ ឬភាពឆ្លាតវៃរបស់អ្នកណាម្នាក់ទេ ខ្ញុំនិយាយជាលក្ខណៈទូទៅរបស់ជនជាតិទាំងពីរ។ ចរិតខ្មែរ និងចរិតវៀតណាម ខុសគ្នាដូចមេឃ និងដី អ៊ីចឹងហើយបានជាខ្មែរមិនសូវចុះសម្រុងនឹងវៀតណាម។

កូនវៀតណាមតូចៗ ប្រឹងរៀនជាងខ្មែរយើង ព្រោះពួកវាដឹងថា បើមិនខំរៀនអក្សរខ្មែរឱ្យចេះទេ វាមិនអាចរស់លើដីខ្មែរនេះបានស្រួលទេ។ កូនវៀតណាម ប្រឹងរៀនណាស់ គួរឱ្យសរសើរ ហើយក៏គួរឱ្យខ្លាចដែរ។ បើសិនជាកូនអ្នកមានផង ម៉ែឪគេចាយលុយរហូតដើម្បីឱ្យកូនគេចេះអក្សរ។ បើបានខ្លាំងជាងកូនខ្មែរ គេកាន់តែសប្បាយចិត្ត។

កូនវៀតណាមធំឡើង ឆេវឆាវជាងខ្មែរបន្តិច ព្រោះម៉ែឪគេមិនធម្មតា។ តែដល់ធំដឹងក្តីបន្តិច គេចាប់ផ្តើមស្វែងរកឱកាសចូលរកកន្លែងអំណាចហើយ។ បើរកកន្លែងអំណាចមិនឃើញទេ គេរកកន្លែងរកលុយឱ្យបានច្រើនសិន។ វៀតណាមដឹងថា លុយ និងអំណាចទៅណាមិនឆ្ងាយគ្នាទេ។ ឱ្យតែមានលុយ មានផ្លូវរកអំណាចបានហើយ។ ឱ្យតែមានអំណាច គឺអាចរកលុយដែលចំណាយទៅបានមកវិញហើយ។

ចំណុចតែមួយដែលខ្ញុំមិនសូវចូលចិត្ត គឺវៀតណាមមិនហ៊ានទទួលស្គាល់ថាខ្លួនឯងជាវៀតណាមទេ។ ភាគច្រើនកុហកថាខ្លួនឯង ជាកូនចៅចិន។ តែបើគិតឱ្យដល់បន្តិច យើងនឹងឃើញថា វៀតណាមពិតជាឆ្លាតមែន។ គេដឹងថាខ្មែរឱ្យតម្លៃលើចិន ហើយម្យ៉ាងទៀតចិត្តស្អប់វៀតណាមរបស់ខ្មែរ មិនទាន់រលត់ទេ។ ចិន ឬយួន មិនសំខាន់ទេ អ្វីដែលសំខាន់តើគេរកបាន

ប្រយោជន៍ប៉ុណ្ណា។

១២៤ - វៀតណាមមិនចូលចិត្តរូបភាពនិយមទេ តែខ្មែរចូលចិត្តណាស់។

១២៥ - វៀតណាមមិនខ្វល់ពីមោទនភាពជាតិរបស់ខ្មែរទេ។ មោទនភាពជួយអ្វីមិនបានទេ។

១២៦ - អ្វីដែលវៀតណាមធ្លាប់ធ្វើ គេនឹងធ្វើម្តងទៀត នៅពេលឱកាសគេមកដល់។

១២៧ - ដោយសារតែមិនចេះគិត ទើបរស់នៅតាមគេញ្ញាក់។

រស់នៅតាមគេញ្ញាក់ វាយ៉ាងម៉េច? ចាំខ្ញុំប្រាប់។ បើគេថា រឿងនេះល្អ យើងក៏ថាល្អ។ គេប្រាប់ថា អ្នកនោះជាមនុស្សល្អ យើងក៏ថាតាមគេដែរ។ ឃើញគេរៀនជំនាញនេះបានលុយច្រើន ខ្លួនឯងក៏ទៅរៀនតាមគេដែរ។ ឃើញគេចូល Comment រិះគន់អ្នកដទៃ ខ្លួនឯងក៏ចូលរិះគន់ដែរ។

នៅមានច្រើនទៀត សរសេរមិនអស់ទេ។

រស់នៅតាមគេញ្ញាក់ បានន័យថា មានខួរក្បាលតែមិនព្រមប្រើ។ សូមទោស ខ្ញុំច្រលំទេ តាមពិត ប្រើដែរ តែប្រើដើម្បីញ្ញាក់តាមគេប៉ុណ្ណោះ។

១២៨ - យើងត្រូវរៀនគិតដោយខ្លួនឯងខ្លះ ទើបស្គាល់ខ្លួនឯង និងស្គាល់សេរីភាព។ បើចាំតែថាតាមអ្វីដែលអ្នកដទៃគិត មួយជីវិតយើងនឹងបម្រើគំនិតអ្នកដទៃជានិច្ច។

មិនបាច់យល់ស្របជាមួយអ្វីដែលខ្ញុំសរសេរទេ តែត្រូវប្រើខួរក្បាលរបស់

យើងមកគិតវាដោយខ្លួនឯងទៅបានហើយ ។

១២៩ - តើយើងគួរជឿលើខ្លួនឯង ឬគួរជឿលើព្រេងវាសនា?

តើយើងគួរពឹងលើអ្នកនយោបាយ ឬពឹងលើសមត្ថភាពខ្លួនដើម្បីរស់នៅ?

តើយើងគួរស្រែកតាមគេថា ស្នេហាជាតិ ឬគួរធ្វើអ្វីខ្លះដើម្បីជាតិខ្លួនឯង?

តើយើងគួរចំណាយពេលជាមួយរឿងគ្មានការបានដែលខាង Media ចង់ឱ្យយើងតាមដាន ឬចំណាយពេលដើម្បីអភិវឌ្ឍខ្លួនឯង?

ធ្លាប់សួរសំណួរទាំងនេះ ។ បើមិនធ្លាប់ទេ ល្អហើយ ដល់ពេលដែលយើងគិតម្តងហើយ ព្រោះតាំងពីក្មេងមក គេប្រាប់យើងឱ្យធ្វើតាមគេរហូត ។

១៣០ - ទាល់តែយើងហ៊ានកាត់ខ្សែដែលគេចង់យើងពីកំណើតសិន ទើបយើងមានសេរីភាព ។ ខ្សែភាគច្រើនជាជំនឿប៉ុណ្ណោះ ។

១៣១ - មនុស្សដែលពូកែអែបអប ក៏ពូកែវាយឬកដែរ ។

១៣២ - ខ្ញុំដូចមិនសូវយល់សោះ ។ បើថាយើងមិនចូលចិត្តអ្នកណាមួយ ឬមិនឯកភាពនឹងរឿងអ្វីមួយ យើងនៅខំមករវល់ជាមួយអ្នកនោះ ឬរឿងនោះធ្វើអីទៀត ។

បើយើងមិនចូលចិត្តផេកនេះទេ ទៅមើលផេកផ្សេងទៅ ។ ហេតុអីចំណាយពេលអត់ប្រយោជន៍លើផេកនេះធ្វើអី? ទុកពេលទៅធ្វើអីផ្សេងទៅ ។ ចំណាយពេល១០នាទី ឬ២០នាទី ដើម្បី comment លើអ្វីមួយដែលយើង

មិនយល់ស្រប តើបានអីមកវិញ? ស្មានតែ Comment ហើយ នឹងមានអ្វីកើតឡើងមែន។

សម្រាប់អ្នកដែលមិនដឹងថាមូលដ្ឋានរបស់ហ្វេសប៊ុកផេក ជាអ្វី ចាំខ្ញុំប្រាប់។ ខាងក្រុមហ៊ុនគេបង្កើតផេកឡើងមក ដើម្បីឱ្យអ្នកដែលមានគំនិតដូចគ្នា ឬអ្នកដែលមានចំណូលចិត្តដូចគ្នា បានស្គាល់គ្នា និងបានផ្លាស់ប្តូរគំនិតទៅវិញទៅមក។

ហើយគេធ្វើអ៊ីចឹងដើម្បីអី? គឺគេចង់ឱ្យគំនិតមួយបានរីកចម្រើនធំជាងមុន។ បើយើងយកមនុស្សដែលមានការគិតផ្ទុយគ្នាមករួមគ្នាដើម្បីពិភាក្សា ស្អីក៏ធ្វើមិនចេញដែរ។ ខ្ញុំផុសនេះដោយសារខ្ញុំគិតថា យើងប្រើភាសាខ្មែរដូចគ្នា ហេតុនេះ គួរតែអាចយល់គ្នាទៅវិញទៅមក។ ទុកពេលរបស់យើងទៅធ្វើអីដែលយើងចូលចិត្តចុះ កុំចំណាយពេលអត់ប្រយោជន៍ជាមួយអ្វីដែលយើងមិនចូលចិត្ត។

១៣៣ - មានលុយ មានអ្នកទ្រពង។

១៣៤ - នៅពេលយើងកាន់តែចាស់ទៅ យើងនឹងកាន់តែជឿសម្តីមនុស្សកាន់តែតិចជាងមុន។

១៣៥ - មិនថាយើងជឿសាសនា ឬមិនជឿទេ បើយើងធ្វើល្អ គេហៅយើងថាមនុស្សល្អ។ បើយើងធ្វើរឿងមានប្រយោជន៍ គេហៅយើងថាជាមនុស្សមានប្រយោជន៍។

បើយើងធ្វើរឿងអាក្រក់ យើងនឹងបានលុយ និងពួកមនុស្សទ្រពងគេមក

ជុំវិញខ្លួនយើងតែម្តង។ តែបានបែបនេះ ទាល់តែយើងចេះលាក់ដែរ មិនត្រូវឱ្យគេដឹងថាយើងអាក្រក់ទេ។

ខែមិថុនា ឆ្នាំ២០១៦

១៣៦ - បើសិនជាគ្រួសារក្រមួយ កើតបានកូនម្នាក់ កូននោះអាចនឹងក្លាយជាអ្នកមាន បើវាចេះប្រឹងប្រែង និងដឹងពីវិធីមាន។ ប៉ុន្តែបើគ្រួសារដែលធ្វើតែរឿងអាក្រក់ (គិតខ្លួនឯងទៅ) ហើយមានលុយ នោះកូនវានឹងដើរតាមគន្លងរបស់ម្តាយឪពុកវាបន្តទៀត ព្រោះវាដឹងថា ធ្វើអាក្រក់បានលុយ។

វាទៅណាមិនឆ្ងាយពីគ្នាទេ ថាមិនត្រូវអាក្រក់ជាម្តាយឪពុកវាផង។ ស្លឹកឈើអាក្រក់ ជ្រុះមិនឆ្ងាយពីអាក្រក់។

១៣៧ - មនុស្សអាក្រក់ មិនមែនកើតពីការមិនជឿសាសនាទេ។ វាកើតមកពីការលោភលន់។ និយាយតែដើមគេរាល់ថ្ងៃ តែទៅវត្តរហូត តើនេះហៅថាមនុស្សល្អទេ?

១៣៨ - សាសនា ជាដំបៅរបស់ខ្មែរ។ ឱ្យតែអ្នកណាហ៊ាននិយាយប៉ះ នឹងត្រូវគេស្តីឱ្យមិនខាន។ ខ្ញុំសរសេរមិនមានបំណងឱ្យអ្នកទាំងអស់គ្នាឈប់ជឿសាសនាទេ ហើយក៏មិនឱ្យមកជឿខ្ញុំដែរ។ ខ្ញុំគ្រាន់តែសរសេរឱ្យគិតអ៊ីចឹង បើមិនចង់គិតទេ កុំអានអ្វីដែលខ្ញុំសរសេរទៅ ចប់ហើយ។

១៣៩ - មានបងប្អូនខ្ញុំម្នាក់ សួរខ្ញុំថា តើបញ្ហាអីខ្លះដែលសង្កត់ខ្មែរមិនឱ្យងើបរួច? ខ្ញុំឆ្លើយភ្លាមថា សាសនា។ ខ្ញុំនឹកឃើញតែមួយនេះទេ ពេលនោះ

ហើយនឹកឃើញភ្លាមតែម្តង។

ខ្ញុំជឿថាព្រះពុទ្ធសាសនា មានការអប់រំល្អ តែខ្ញុំមិនជឿរបៀបដែលគេយកសាសនាមកអនុវត្តទេ។ ព្រះពុទ្ធសាសនា ជាទស្សនវិជ្ជាល្អមួយ តែសព្វថ្ងៃត្រូវបានគេយកមកប្រើប្រាស់ ដើម្បីរកលុយ រកអំណាច រកមុខមាត់ និងធ្វើឱ្យមនុស្សខាតពេល។

១៤០ - សាសនា មិនបានជួយឱ្យមនុស្សធ្វើល្អទេ ជួយបានត្រឹមតែឱ្យមនុស្សធ្វើពុតជាល្អប៉ុណ្ណោះ។ មនុស្សទើបជាអ្នកសម្រេចថាធ្វើល្អ ឬធ្វើអាក្រក់។

១៤១ - អ្វីដែលជាការពិត វាប្រហែលជាប្លែកបន្តិចហើយ។

១៤២ - អ្នកនយោបាយ មិនចង់ឱ្យយើងចេះដឹងច្រើនទេ ព្រោះពិបាកបោក។ នេះជាការពិតមួយ។ គេចង់ឱ្យចេះដឹង ត្រឹមតែអាចបម្រើមហិច្ឆតាគេបានប៉ុណ្ណោះ មិនចង់ឱ្យយើងប្រឆាំងជាមួយគេទេ។ បើគេចង់ឱ្យប្រជាពលរដ្ឋចេះដឹង ពេលចែកអំណោយ គេដឹកសៀវភៅអានមកចែកហើយ មិនមែនយកសារុងមកចែកទេ។

យើងអាចសួរថា ចុះគេចែកសៀវភៅឱ្យក្មេងៗអាននោះ មិននិយាយផង។ តែក្មេងអានសៀវភៅទាំងនោះហើយ យល់ពីអីខ្លះ? អត់ទេ។ គេឱ្យសៀវភៅទៅមនុស្សដែលគ្មានលទ្ធភាពគិតដោយខ្លួនឯង ហើយឱ្យសារុងទៅមនុស្សដែលធំដឹងក្តីហើយ។

១៤៣ - ទីបំផុត ខាងលោកឧកញ៉ា គួច ម៉េងលីបានផ្ញើរសារមកឱ្យខ្ញុំ

ហើយ។ គេប្រាប់ឱ្យខ្ញុំលុបពាក្យថា "លោកឧកញ៉ាលេបសម្ដី" ចេញពីប្លុករបស់ខ្ញុំ។ គេបានប្រាប់ថា ដោយសារលោកឧកញ៉ាមានការរវល់ ហើយហ្វេសប៊ុករបស់គាត់ បានប្រគល់ឱ្យលេខាកាន់ជំនួសវិញ ទើបមិនបានឆ្លើយតបនឹងសាររបស់ខ្ញុំ (តែខ្ញុំផ្ញើរទៅ៣ដង)។

គេបានប្រាប់ថា ការដែលខ្ញុំសរសេរបែបនេះ គឺប៉ះពាល់ដល់ភាពថ្លៃថ្នូរបស់លោកឧកញ៉ាខ្លាំងណាស់។ តែគេភ្លេចថា អ្វីដែលលោកឧកញ៉ាធ្វើក៏ប៉ះពាល់ដល់ទឹកចិត្តរបស់ខ្ញុំដែរ នៅមានម៉ាក់ខ្ញុំទៀត ព្រោះខ្ញុំបានប្រាប់ម៉ាក់ខ្ញុំថា មានគេចង់ជួយបោះពុម្ពសៀវភៅឱ្យខ្ញុំ។

ខ្ញុំក៏លុបឱ្យទៅ ព្រោះគេផ្ញើរសារមកត្រឹមត្រូវដែរ អ៊ីចឹងយើងធ្វើត្រឹមត្រូវទៅវិញទៅ។

គេហៅខ្ញុំទៅជួបដើម្បីនិយាយរឿងសៀវភៅ ហើយគេប្រាប់ថា លោកឧកញ៉ាបានឱ្យកញ្ចប់លុយដើម្បីបោះពុម្ពសៀវភៅរបស់ខ្ញុំទៀតផង។ អាណាប៊ានទៅលោក? កុហកម្ដងហើយ ទៅទៀតមានតែខាតពេលកន្លះឆ្នាំទៀត។ ខ្ញុំទុកសរសេរសៀវភៅជា Ebook វិញ បើខ្ញុំចង់លក់ ក៏លក់ជា ebook ដែរ កុំឱ្យរំខានគេរំខានឯងច្រើន។

ខ្ញុំបានមេរៀនហើយ ខ្ញុំមិនទៅរៀនមេរៀនដដែលម្ដងទៀតទេ។ កុំជឿពាក្យអ្នកមាន កុំជឿពាក្យចិន និងកុំជឿពាក្យមនុស្សដែលមានងារជាឧកញ៉ា។

១៤៤ - ចំណេះដឹងខ្លះ គ្រាន់តែល្អមើលប៉ុណ្ណោះ មិនអាចប្រើការបានទេ។

ចូលមើលវេបសាយមួយចំនួនរបស់ខ្មែរយើងទៅ ដឹងហើយ។

១៤៥ - គ្មានអ្នកក្រោកឈរដើម្បីចំណេះដឹងពិត ទើបគ្មានការរីកចម្រើន។

១៤៦ - ភ្លើសមប៉ុណ្ណា ក៏គេនៅតែហៅថាភ្លើដែរ។ បើជៀសបាន ជៀសទៅ ព្រោះការធ្វើភ្លើតាមគេនេះ គ្មានបានអីមកវិញទេ។

១៤៧ - បើគ្មានគេដឹកនាំយើង យើងអត់បាយស៊ីមែន? បើអត់មែន មិនមែនមកពីគេទេ គឺមកពីខ្លួនយើង។

១៤៨ - ដោយសារយើងរស់នៅក្នុងប្រព័ន្ធដែលគេរៀបចំយូរពេក ទើបយើងមិនចង់ចាកចេញ។ សាសនា នយោបាយ ការអប់រំ ទីផ្សារ និងសូម្បីតែហ្វេសប៊ុកដែលយើងកំពុងប្រើនេះ សុទ្ធតែជាប្រព័ន្ធ។ ប្រព័ន្ធបែបនេះបង្កើតជំនឿម្យ៉ាងម្នាក់។ អ្វីដែលអាក្រក់ គឺជំនឿទាំងនេះ ខុសពីការពិត។

១៤៩ - គេបោកយើងបាននៅពេលដែលយើងល្ងង់ និងពេលដែលយើងគិតថាយើងឆ្លាតជាងគេ។

១៥០ - មនុស្សបោកប្រាស់ គ្មានថ្ងៃទទួលស្គាល់ការពិតទេ។

១៥១ - ហេតុអ្វីបានជាមនុស្សមិនហ៊ានទទួលស្គាល់ការពិត?

មូលហេតុមានដូចជា៖

-ខ្លាចការពិត គិតថាអ្វីដែលខ្លួនដឹង វាល្អសម្រាប់ខ្លួនហើយ។ អ្នកខ្លះមិនហ៊ានទទួលស្គាល់ថា អ្នកនយោបាយជាមនុស្សបោកប្រាស់ ព្រោះបើទទួលស្គាល់បែបនេះ ពួកគេនឹងអស់ទីពឹងពាក់ មិនដឹងជាត្រូវជឿអ្នកណាទៀត។

-មិនជឿថាខ្លួនឯងល្ងង់ មិនស្គាល់ការពិត។ អ្នកខ្លះដឹងហើយថា រឿងនេះជាការពិត តែមិនទទួល ព្រោះបើទទួលទៅស្មើនឹងខ្លួនឯងល្ងង់។ ខ្លាចគេថាល្ងង់ ហេតុនេះសុខចិត្តរស់នៅជាមួយនឹងពាក្យបោកប្រាស់។ មនុស្សយើងខ្លាចល្ងង់ តែសុខចិត្តបោកខ្លួនឯងថាឆ្លាត។

-ជាមនុស្សបោកប្រាស់។ មានតែអ្នកនយោបាយគ្នាគេទេ ទើបនិយាយថាអ្នកនយោបាយមិនដែលបោកប្រាស់។ មនុស្សបោកប្រាស់ គ្មានថ្ងៃទទួលស្គាល់ការពិតទេ។

១៥២ - នេះជាសំណួរដែលខ្ញុំបានទទួល។ ខ្ញុំឆ្លើយតាមកម្រិតខួរក្បាលរបស់ខ្ញុំទេ។

បើខុស ក៏ខុសទៅ ព្រោះខ្ញុំឆ្លើយខុសរាប់មិនអស់ទៅហើយ។

" ព្រោះតែមិនចង់នៅក្បែរពួកវាហ្នឹងហើយទើបចូលរួមធ្វើនយោបាយ នឹងតាមដានអ្នកនយោបាយ បើមិនចូលរួមនឹងនយោបាយទេ តើមានមធ្យោបាយមួយណាអាចនៅឆ្ងាយពីពួកវា បើវាចេះតែមកនៅក្បែរយើងដូចសព្វថ្ងៃនេះ? "

នយោបាយគេមិនធ្វើដើម្បីរឿងហ្នឹងទេ។ នយោបាយ គេធ្វើដើម្បីឡាននិងមុខមាត់ក្នុងប្រវត្តិសាស្ត្រប៉ុណ្ណោះ។

មធ្យោបាយនៅឆ្ងាយពីយួន គឺខ្លួនយើងខ្លាំងជាងយួន មានជាងយួន ឆ្លាតជាងយួន និងមិនគាំទ្រយួន។ វាមកក្បែរយើងបាន ដោយសារមានអ្នកគាំទ្រពួកវា និងដោយសារយើងគ្មានលទ្ធភាពទិញដីពីវា។ រាល់ថ្ងៃមានតែយួន

ទិញដីពីខ្មែរ គ្មានខ្មែរណាមានលុយទិញដីពីយួនទេ។ ជួនកាល ចូលរួមធ្វើនយោបាយហ្នឹងហើយ ដែលនាំយួនចូលស្រុកនោះ។ នៅចាំប្រវត្តិសាស្ត្រខ្មែរយើងទេ។ អ្នកនយោបាយណាខ្លះ ប្រជាពលរដ្ឋណាខ្លះ ដែលចាញ់បោកយួន ហើយនាំយួនចូលស្រុក?

តាមពិត ខ្ញុំមិនដឹងថាត្រូវធ្វើយ៉ាងណាដែរទេ។ តែខ្ញុំដឹងថា បើជនជាតិខ្មែរខ្លាំងជាងយួន និងចេះស្នេហាជាតិច្រើនជាង យើងនៅតែអាចរក្សាប្រទេសយើងបានដដែល។

ខ្មែរយើងរាល់ថ្ងៃមានមោទនភាពជ្រុលហើយ ជ្រុលរហូតដល់ភ្លេចថាខ្លួនឯងនៅទន់ខ្សោយ។ ខ្មែរមិនចង់ចេះដឹងទេ ចូលចិត្តតែការសប្បាយដែលពួកយួនលួចបង្កើតឱ្យ។ ខ្មែរមិនស្រលាញ់ជាតិទេ តែស្រលាញ់ផលប្រយោជន៍ដែលបានពីជាតិ ហើយប្រយោជន៍នោះក៏យួនផ្តល់ឱ្យដែរ។ ខ្មែរមិនគាំទ្ររបស់ខ្លួនឯងទេ ចេះតែជោរតាមគ្នាមួយភ្លែតប៉ុណ្ណោះ។ កុំឃើញខ្មែរចេះទិញក្រមា ថាខ្មែរគាំទ្រជាតិសាសន៍ឯងឱ្យសោះ។

សូមទោសចុះ ខ្ញុំលែងជឿនយោបាយស្រុកខ្មែរតាំងពីខ្ញុំទៅហែរបក្សសង្គ្រោះជាតិម្ល៉េះ។ ពេលដែលខ្ញុំទៅដល់ ខ្ញុំឃើញសុទ្ធតែកូនយួននៅក្បែរផ្ទះខ្ញុំ។ ហើយពួកវាមកសង្គ្រោះស្អីដែរ? ខ្ញុំក៏នឹកឃើញដល់កាលយួនមកសង្គ្រោះខ្មែរឆ្នាំ ៧៩ និងរូបភាពដែលគេផុសថា វាដុតផ្ទះខ្មែរ ហើយមកជួយបាញ់ទឹក។ ខ្ញុំចាប់ផ្តើមដឹងថា នយោបាយជាសាច់រឿងដែលគេប៉ុណ្ណោះ។ បើមិនចង់នៅជិតយួន ត្រូវប្រឹងខ្លួនឯង។

កាត់ប៉ុណ្ណឹងចុះ កុំឱ្យវែងពេក។

១៥៣ - យួន ជាជាតិសាសន៍មួយដែលមានស្រលាញ់ជាតិខ្លួនណាស់។ គេមិនក្បត់ជាតិខ្លួនដើម្បីខ្មែរទេ។ ទោះជាកើតនៅលើដីខ្មែរក៏ដោយ មានសញ្ជាតិខ្មែរក៏ដោយ យួននៅតែស្រលាញ់ប្រទេសរបស់ខ្លួនជានិច្ច។ មិនមែនស្រលាញ់តែមាត់ទេ គឺធ្វើដើម្បីប្រទេសវាទៀត គ្រាន់តែយើងមិនចាប់អារម្មណ៍ប៉ុណ្ណោះ។

អ្នកទាំងអស់គ្នាកុំភ្លេចចំណុចនេះ។

១៥៤ - អូ! កុំឱ្យគេបោកបានងាយពេក។ កុំដោយសារតែគេប្រើ ពាក្យដើម្បីជាតិ ហើយយើងនាំគ្នាជឿដោយមិនគិតអ្វីនោះ។

បើអ្នកទាំងអស់គ្នាចេះស្រលាញ់ជាតិមែន ប្រឹងធ្វើអ្វីខ្លះដើម្បីជាតិមក តាមសមត្ថភាពរបស់យើង។ ស្រលាញ់ជាតិ បានន័យថាយើងជួយទ្រទ្រង់ផ្នែកណាមួយរបស់ជាតិ ព្រោះមានប្រជាជនខ្មែរមានច្រើនណាស់ យើងចែកគ្នាតាមផ្នែកទៅ។ អ្នកណា ពូកែខាងកីឡា លើកស្ទួយកីឡាទៅ អ្នកណាពូកែខាងផ្នែកប្រវត្តិសាស្ត្រ ខំប្រឹងផ្សព្វផ្សាយឱ្យអ្នកដទៃដឹងលឺទៅបានហើយ។

បើយើងចង់ធ្វើដូចអ្នកនយោបាយ ដែលស្អីក៏គាត់ធ្វើបាន ស្អីក៏គាត់រ៉ាប់រ៉ងដឹងតែទៅមិនរួចហើយ។ អ្នកនយោបាយផ្សេង យើងផ្សេង អត់មានអីដូចគ្នាទេ។ គេធ្វើដើម្បីប្រយោជន៍គេ យើងធ្វើដើម្បីប្រយោជន៍យើង និងប្រទេសដែលយើងរស់នៅ។

ជឿក៏បាន មិនជឿក៏បាន តែបើនៅតែឆ្កួតនឹងអ្នកនយោបាយទៀត មិនយូរទេ អ្នកទាំងអស់គ្នានឹងរស់នៅក្បែរ ពួក អេមម៉ឺយឱដូវ ហើយ។ ខ្ញុំមិន

ចង់រស់នៅជិតពួកវាទេ បានជាប្រាប់អ្នកទាំងអស់គ្នា។

ពួកវាឆ្លាតជាងយើងឆ្ងាយណាស់។ វាសប្បាយចិត្ត ពេលឃើញខ្មែរនៅតែភ្លើ ឈ្លោះគ្នាដើម្បីអំណាចរបស់អ្នកនយោបាយ។ វាពេញចិត្តនៅពេលឃើញខ្មែរគិតថាខ្លួនឯងមានមោទនភាព រហូតភ្លេចខ្លួន។ វាប៉ងយកយូរហើយ វាមិនដែលឈប់ទេ ហើយខ្មែរយើងក៏ដឹងគ្រប់គ្នាដែរ។ នេះមិនមែនជារឿងនយោបាយទេ នេះជារឿងរបស់សង្គមយើង។ ខ្ញុំមិនចង់ដើរទៅណាក៏ឃើញមុខពួកវាទេ។

១៥៥ - សង្គមមួយនាំគ្នាភ្លើ ព្រោះជឿតាមមនុស្សភ្លើ។

១៥៦ - ល្ងង់ ក៏ល្ងង់ចុះ តែកុំភ្លើ។ បើដឹងថាអ្វីមួយមិនល្អហើយ កុំធ្វើ កុំគាំទ្រ និងជួយរកលេសឱ្យវា។

១៥៧ - ខ្ញុំចិត្តចង្អៀតណាស់ មិនចូលចិត្តអ្នកណាមកប៉ះពាល់កម្មសិទ្ធិខ្ញុំទេ ហើយខ្ញុំក៏មិនទៅប៉ះពាល់របស់អ្នកណាដែរ។ តែខ្ញុំចេះពីវិធីចែករំលែក ។ ខ្ញុំដឹងថា មិនបាច់ទាល់តែមានលុយ ទើបអាចចែកបានទេ ។ ខ្ញុំមានបណ្ណា ខ្ញុំចែកប៉ុណ្ណឹង ។

ខ្ញុំចេះសរសេរសៀវភៅ ខ្ញុំចែកសៀវភៅ។ ខ្ញុំចេះធ្វើរូប ខ្ញុំចែកជារូបភាព។ តែខ្ញុំមិនលួចរបស់អ្នកណាមកចែកដើម្បីយកមុខមាត់ទេ។

គេមិនខ្លាចមនុស្សចិត្តចង្អៀតទេ គេខ្លាចតែ មនុស្សមិនព្រមចែករំលែក។ មនុស្សច្រើនណាស់ដែលមានចិត្តទូលាយ តែមិនធ្លាប់ចែកអ្វីបន្តិចទេ។ មូលហេតុ គឺមិនដឹងថាចែកអី និងធ្វើពុតជាចិត្តទូលាយ។

១៥៨ - ដោយសារតែខ្ញុំមិនមានកេរ្តិ៍ឈ្មោះ និងលុយច្រើន ក្នុងសង្គម ពេលដែលខ្ញុំប្រាប់ថា អ្នកនេះនិយាយកុហក មិនរក្សាសម្តី គ្មានអ្នកណាជឿខ្ញុំទេ។ គេគិតថាខ្ញុំនិយាយបង្ខូចឈ្មោះគេ។ ខ្ញុំគ្រាន់តែប្រាប់ទេ ព្រោះខ្លាចចាញ់បោកមនុស្សដែលពាក់មុខល្អតាមអេក្រង់ដូចខ្ញុំ។

ដោយសារតែផេកខ្ញុំ មិនមានគេស្គាល់ច្រើន ពេលដែលមានផេកល្បីជាងយកសៀវភៅទៅផុស ហើយខ្ញុំទាមទារសិទ្ធិរបស់ខ្ញុំមកវិញ គេនាំគ្នាថា ខ្ញុំចិត្តចង្អៀត ប្រកាន់ច្រើន មិនចេះចែករំលែកចំណេះដឹង។ តែសាកគិតទៅមើល សៀវភៅ គឺខ្ញុំជាអ្នកសរសេរ បើខ្ញុំមិនផុសនៅលើអ៊ីនធឺណេត តើអាចមានផេកផ្សេងទៀតយកទៅផុសបានទេ?

ដោយសារតែខ្ញុំ ជាអ្នករៀនអាយធី ពេលដែលខ្ញុំនិយាយពីច្បាប់កម្មសិទ្ធិបញ្ញា និងសិទ្ធិអ្នកនិពន្ធ គេនាំគ្នាថា ខ្ញុំធ្វើហួសហេតុ។ ច្បាប់នេះ មិនមែនជាច្បាប់ធ្វើបាបគេដូចច្បាប់ផ្សេងទេ។ ច្បាប់នេះ សម្រាប់ការពារស្នាដៃរបស់អ្នកដែលប្រើខួរក្បាលបង្កើតអ្វីមួយប៉ុណ្ណោះ។ ច្បាប់នេះ ត្រូវបានគេបង្កើតឡើងដើម្បីជារង្វាន់ដល់ពួកអ្នកនិពន្ធ ព្រោះគេដឹងថា ពួកនេះរកលុយមិនបានច្រើនទេ ទើបគេចង់លើកទឹកចិត្តខ្លះទៅ។

ខ្ញុំចាប់ផ្តើមខ្លាចស្រុកនេះហើយ។ ម្នាក់ៗតាំងខ្លួនស្នេហាជាតិ ស្រលាញ់អំពើល្អ តែនៅពេលមានការលួចស្នាដៃកើតឡើង នាំគ្នាទៅគាំទ្រការលួចវិញ។ ខ្ញុំយកច្បាប់មកនិយាយ គេនាំគ្នាធ្វើមិនដឹង។

១៥៩ - បើមិនបានជួយបង្កើតទេ កុំបំផ្លាញថែម។ ខ្ញុំចង់ឱ្យចំនួនសៀវភៅដែលបកប្រែពីបរទេស ស្មើគ្នា ឬប្រហាក់ប្រហែលគ្នានឹងចំនួនសៀវភៅ

ដែលនិពន្ធក្នុងស្រុក។ ទោះយើងសរសេរមិនបានល្អដូចគេក៏ដោយ តែវាគ្រាន់បើជាងអត់។

១៦០ - ធ្វើយ៉ាងណាឱ្យតែបានដល់ដៃអញ ចង់លួចពីអាណាមក ក៏អញមិនខ្វល់។ ចង់អាណាស្រែកឱ្យជួយយ៉ាងម៉េច ក៏អញមិនខ្វល់ សំខាន់អញបានអានដោយមិនអស់លុយ។ នេះជាការគិតរបស់អ្នកដែលគាំទ្រផេកចោរនោះ។

១៦១ - សូមកុំចង់បានប្រយោជន៍ពីពួកចោរ ឬការលួច។

ខ្ញុំមិនដឹងជានិយាយយ៉ាងម៉េចចេញទេ នៅពេលមានគេមកប្រាប់ខ្ញុំថា ផេកចោរនោះ ផ្ដល់ប្រយោជន៍ដល់មនុស្ស។ សៀវភៅមិនថ្លៃណាស់ណាទេ ហេតុអីនាំគ្នាការលួចរបស់អ្នកដទៃបែបនេះ?

ខ្ញុំយល់ មនុស្ស មានចរិតអាត្មានិយម។ ធ្វើយ៉ាងណាឱ្យតែបានដល់ដៃអញ ចង់លួចពីអាណាមក ក៏អញមិនខ្វល់។ ចង់អាណាស្រែកឱ្យជួយយ៉ាងម៉េច ក៏អញមិនខ្វល់ សំខាន់អញបានអានដោយមិនអស់លុយ។ នេះជាចរិតអ្នកដែលគាំទ្រផេកចោរនោះ។

ហេតុអីចង់បានប្រយោជន៍រួម ជាមួយចោរទៅវិញ? សួរខ្លួនឯងទៅមើល។ គេលួច យើងចាំយក តើយើងមិនចេះខ្មាសគេទេ ឬម៉េច?

១៦២ - ចេះគាំទ្រ ល្អហើយ តែត្រូវមើលដែរថាវាត្រូវ ឬអត់។ នេះមិនមែនដូចរឿង ចោរចិត្តជា ដែលលួចអ្នកមានទៅជួយអ្នកក្រទេ។ នេះគឺតែលួច សៀវភៅពីម្ចាស់ដើម ហើយយកមកផុសដោយដាក់កម្មសិទ្ធខ្លួនឯង

ទៀត។

១៦៣ - ប្រព័ន្ធអប់រំ ប្រព័ន្ធច្បាប់ ប្រព័ន្ធឃោសនា និងប្រព័ន្ធសាសនា បានធ្វើឱ្យខ្ញុំច្រលំថាអ្វីជារឿងមិនត្រឹមត្រូវអស់។ ប្រព័ន្ធទាំងនេះ ប្រាប់ខ្ញុំថា អ្វីដែលត្រូវស្អប់ និងអ្វីដែលត្រូវស្រលាញ់។

១៦៤ - ខ្ញុំទើបតែទទួលបាន Comment មួយពីអ្នកអានសៀវភៅថ្មីរបស់ខ្ញុំ។ គាត់ថា ចំណុច "ប្រភពរបស់សៀវភៅ" មិនបាច់ដាក់ក៏បានដែរ ព្រោះវាមានលក្ខណៈវាយប្រហារចំៗ។

ខ្ញុំមិនមែនវាយប្រហារទេ គឺខ្ញុំចង់ប្រាប់ថា សៀវភៅនេះ ខ្ញុំដកយកគោលគំនិតពីសៀវភៅរបស់លោក ឧកញ៉ា គួច ម៉េងលី។ ហេតុអី ខ្ញុំត្រូវលាក់ឈ្មោះគាត់ បើខ្ញុំយកពីសៀវភៅគាត់មែនហ្នឹង?

តាមពិតមិនមែនជាការវាយប្រហារទេ ខ្ញុំគ្រាន់តែនិយាយថា គាត់លេបសម្តីដែលនិយាយថា ជួយបោះពុម្ពសៀវភៅឱ្យខ្ញុំ។ នេះជាបទពិសោធន៍ដែលខ្ញុំជួបពិតៗ ហើយខ្ញុំយកមកចែករំលែកឱ្យអ្នកដែលមិនទាន់ជួប។ អ្នកដែលអានហើយ ទៅចាប់អារម្មណ៍តែឈ្មោះ លោកឧកញ៉ាទៅវិញ មិនចាប់អារម្មណ៍នឹងមេរៀនដែលខ្ញុំសរសេរ។

អានសៀវភៅ គេអានដើម្បីស្រង់ចំណុចសំខាន់ មិនមែនស្រង់ឈ្មោះទេ។ សៀវភៅខ្ញុំ មិនមែនជាសៀវភៅប្រវត្តិសាស្ត្រទេ ដូច្នេះក៏ផ្តោតលើឈ្មោះខ្លាំងពេក។

គាត់បាន Comment ទៀតថា "ចង់ឬមិនចង់ ពិតឬមិនពិត គឺមិនគួរដាក់

ឬមិនគួរសរសេរ។" What? ចង់មិនចង់អី ខ្ញុំសរសេរឱ្យគេបានដឹងថា រឿងដែលយើងរំពឹងទុក វាមិនកើតឡើងរហូតទេ។ ហើយនេះ ខ្ញុំក៏រៀន តាមអ្វីដែលលោកឧកញ៉ានោះ បានបង្រៀនខ្ញុំដែរ។ ខ្ញុំមានទាំង Recordingសម្លេងដែលគាត់ប្រាប់ខ្ញុំទៀតផង។ គាត់ប្រាប់ថា កុំឱ្យខ្លាច គេ មានអីចង់និយាយ ក៏និយាយទៅ។ កុំទ្រពងគេ។

ឥលូវខ្ញុំនិយាយហើយ គាត់លេបសម្ដី។ ខ្ញុំមិនបានថាគាត់ជាមនុស្សអាក្រក់ ធ្វើរឿងបំផ្លាញជាតិអីទេ។ ខ្ញុំថា គាត់កុហកខ្ញុំ។ និយាយត្រង់មិនបាន។

ខ្ញុំដឹង សម័យនេះ គេចូលចិត្តស្ដាប់ និងអានពាក្យបោកប្រាស់។ ដូច្នេះ ពេលដែលមានគេនិយាយការពិត នឹងមានមនុស្សមកហាមបែបនេះហើយ។ ខ្ញុំមិនភ្លើទេ ការពិតនេះ មិនប៉ះពាល់ដល់លោកឧកញ៉ានោះទេ ព្រោះវាជារឿងធម្មតាទៅហើយ ដែលមនុស្សលេបសម្ដី។

ម្ចាស់ Comment បើឃើញហើយ កុំគិតថាខ្ញុំកំពុងថាឱ្យ អី។ ខ្ញុំមិនបាន ថាឱ្យទេ ខ្ញុំគ្រាន់តែពន្យល់បងឱ្យយល់ប៉ុណ្ណោះ។ របៀបពន្យល់របស់ខ្ញុំ អាចអត់សីលធម៌ តែខ្ញុំអត់បានថែមគ្រឿងចូលទេ។

ខ្ញុំនិយាយពីការសរសេរសៀវភៅ។ បើអ្នកនិពន្ធសរសេរមិនពិតដដែល ទុកដៃដេកសាប់ខ្លួនឯងទៅ កុំសរសេរអ្វីដែលធ្វើឱ្យគេអានហើយ ខាតពេល។

**ខែឧសភា ឆ្នាំ២០១៦**

១៦៥ - គន្លឹះងាយៗដើម្បីក្លាយខ្លួនជាកូនខ្មែរស្នេហាជាតិ ៖

-ពាក្យថា "ខ្មែរ" ឱ្យបានច្រើន។

-តាមដានទំនោរសង្គមឱ្យជាប់។ បើគេបត់ទៅខាងណា យើងត្រូវទៅឱ្យលើសគេ។ ឧទាហរណ៍ ពេលគេកំពុងតែគាំទ្របាល់ទាត់ យើងត្រូវចេញមុខឱ្យបានខ្លាំងជាងគេ ទោះបីយើងមិនចូលចិត្តមើលបាល់ទាត់ក៏ដោយ។

-ជេរគេ ជេរឯង។

ងាយម្ល៉េះ ! គ្រាន់តែធ្វើតាមចំណុចទាំង៣នេះ ខ្ញុំក៏អាចក្លាយជាអ្នកស្នេហាជាតិបាត់ទៅហើយ។ ឆ្ងល់ដែរ ចាស់ៗជំនាន់មុនចាំបាច់ខំប្រឹងទៅស្លាប់ក្នុងសង្គ្រាម សុខចិត្តដាច់បាយ លះបង់ពេលវេលាបង្កើតអ្វីសម្រាប់ជាតិធ្វើអី បើធ្វើតែប៉ុណ្ណេះគេថា ស្នេហាជាតិហើយហ្នឹង។

បញ្ជាក់ នេះជារឿងកំប្លែងទេ។

១៦៦ - បើមិនចូលចិត្ត កុំមើលតែម្តង។ បើមើលហើយរិះគន់គេដដែល កុំមើល។

១៦៧ - ខ្ញុំទៅដាក់ពាក្យធ្វើការនៅក្រុមហ៊ុនមួួយ។ ក្រុមហ៊ុននោះលក់គ្រឿងសំណង់មិនដឹង ធ្វើសំណង់មិនដឹងទេ។ ពេលទៅសម្ភាសថ្ងៃទី១ ខ្ញុំគិតថាមិនអីទេ ព្រោះគេប្រាប់ខ្ញុំថា ចាំមកសម្ភាសម្តងទៀតជាមួយថៅកែតែម្តង។ ខ្ញុំគិតក្នុងចិត្តថា ប្រហែលជាបានការងារធ្វើទៀតហើយ។

ដល់ថ្ងៃសម្ភាសន៍ទី២ ស្រាប់តែថៅកែនិយាយចេញមកតុងវៀតណាម ខ្ញុំភ្ញាក់ខ្លួនព្រើត តែខំឆ្លើយសំណួរគួរគេទៅ។ គេសួរខ្ញុំថា ចេះគូរ Logo ទេ និងសួរអីច្រើនទៀត។ ខ្ញុំមិនចាំទេ ព្រោះពេលនោះខ្ញុំដឹងថា ខ្ញុំមិនមកធ្វើការនៅក្រុមហ៊ុននោះទេ។

ខ្ញុំឆ្អែតនឹងថៅកែចិនហើយ ខ្ញុំមិនហ៊ានមកប្រឡូកនឹងថៅកែយួនទេ។

បើខ្ញុំធ្វើបែបនេះ គេហៅថាស្នេហាជាតិដែរទេ? អត់ទេ។ ខ្ញុំធ្វើដើម្បីខ្លួនឯងប៉ុណ្ណោះ។ ក្នុងចំណោមថៅកែយួន១០០នាក់ យ៉ាងហោចណាស់មានតែ១០នាក់ប៉ុណ្ណោះដែលរកស៊ីត្រឹមត្រូវ ហើយ១០នាក់នេះអាចនឹងមិនមករកស៊ីនៅស្រុកខ្មែរទេ។ សម្រាប់ខ្ញុំ ពាក្យថា "រកស៊ីត្រឹមត្រូវ" មានន័យលើសពីការចុះឈ្មោះក្នុងបញ្ជីក្រសួងទៀត។ ខ្ញុំមិនចង់ធ្វើអាក្រក់ដោយដៃខ្លួនឯងដើម្បីចិនយួនបានកើបលុយនោះទេ។

កាលខ្ញុំធ្វើការនៅកាស៊ីណូចិន ពួកវាឱ្យខ្ញុំលក់បារី Cigar លក់ស្រា និងលក់ស្អីផ្សេងទៀត។ មកពីមិនចង់ធ្វើអារឿងហ្នឹងហើយ បានជាខ្ញុំរៀនអ្វីផ្សេងដែលមិនពាក់ព័ន្ធនឹងការងារនេះ ដើម្បីយករួចខ្លួន។

មនុស្សខ្ញុំអាត្មានិយមណាស់។ ខ្ញុំធ្វើយ៉ាងណាឱ្យតែខ្លួនឯងបានសុខ ហើយមិនបាច់ទៅបោកអ្នកណាយកលុយ។ តែខ្ញុំឆ្ងល់ដែរ បើខ្ញុំប៉ុណ្ណឹងអាត្មានិយមទៅហើយ ចុះទម្រាំអ្នកដែលស៊ីលុយគេក្រោមតុ កាប់ឈើ លក់គ្រឿងញៀនទៀត មិនដឹងជាទៅស្អីវិញ?

១៦៧ - អ្វីដែលខ្ញុំខ្លាចជាងគេ គឺនៅអនាគតទៅ ខ្ញុំត្រូវរស់នៅជាមួយមនុស្សដែលពូកែទ្រពងគេទាំងនោះ។

១៦៨ - ដោយសារខ្មែរទទួលឥទ្ធិពលចិន ច្រើន ទើបខ្មែរពូកែអួតច្រើន។ តែដោយសារខ្មែរយើង គ្មានសេចក្ដីក្លាហានទទួលស្គាល់អំណួតរបស់ខ្លួនឯង ទើបធ្វើឱ្យមិនអាចងើបរួចពីអំណួតនេះ។

ខ្មែរក្លាហានជាមួយអ្នកដទៃ តែមិនក្លាហានប្រឈមមុខនឹងចំណុចអាក្រក់របស់ខ្លួនឯងទេ។ តាមពិតមិនមែនមានតែខ្មែរយើងទេ ដែលជួបរឿងនេះ តែដោយសារខ្ញុំសរសេរឱ្យខ្មែរមើល ទើបខ្ញុំប្រើតែពាក្យខ្មែរ។

១៦៩ - ជីវិតយើងខ្លីណាស់ កុំចេះតែរិះគន់អ្នកដទៃ។

១៧០ - ពុតចិនកុំត្រាប់ ច្បាប់ចិនសឹមយកតាម។

១៧១ - ចង់ធ្វើមនុស្សល្អ ងាយស្រួលណាស់ គឺកុំធ្វើតាមពួកចិនទៅបានហើយ។

១៧២ - ភាពដូចគ្នារវាងអ្នកនយោបាយខ្លះ និងអ្នកសិល្បៈខ្លះ

-ត្រូវការសម្លេងគាំទ្រ

-ចង់បានលុយ ឆ្លៀតរកអំណាច

-ពូកែសម្តែង

-អាចធ្វើឱ្យយើងសើចបាន

-និយាយល្អពីមុខ ធ្វើរឿងអាក្រក់ក្រោយឆាក

-រៀនតាមលីវប៊ុ បង្ហាញគុណធមិតាមកញ្ចក់ទូរទស្សន៍

-ចូលចិត្តយកពាក្យ "ខ្មែរ" ទៅពាក់ព័ន្ធនឹងខ្លួនឯងដើម្បីឱ្យគេជឿជាក់

-មានរឿងឱ្យយើងតាមដានរហូត

-មិនចង់ឱ្យអ្នកដទៃចេះដឹង ព្រោះខ្លាចគេលែងជឿ

ភាពខុសគ្នា

-អ្នកនយោបាយអាចទិញក្បាលអ្នកសិល្បៈបាន

** អ្វីដែលខ្ញុំសរសេរខាងលើនេះ មិនមែនជាការពិតទេ។ កុំជឿខ្ញុំ។

១៧៣ - ចាំមើលខ្ញុំនិយាយរឿងមួយដែលកើតក្នុងសង្គមមួយ។

ឪពុកវា ជាមនុស្សដែលដេកសុ៊ីលុយរដ្ឋ និងធ្វើបាបប្រជាជនតូចតាច។ កូនវា ដោយសារបានលុយឪដែលរកបានដោយងាយស្រួល និងអាក្រក់បំផុតនោះ ក៏មិនបាច់ខ្វល់ពីរឿងធ្វើការអីដែរ។ វាដឹងតែបើកភ្នែកឡើងហុចដៃទារលុយ តែម្តង។

វាចាយលុយស្រួលពេក វាក៏នឹកឃើញវិធីមួយដើម្បីយកបានឈ្មោះជាមនុស្សល្អ។ វាមិនចង់ធ្វើជាមនុស្សល្អទេ ព្រោះវាដឹងថាមនុស្សល្អ ក្រយូរណាស់ ទាល់តែស្លាប់ទើបមានដោយសារកូនចៅដុតលុយខ្មោចឱ្យ។ ប៉ុន្តែវាគ្រាន់តែចង់បានឈ្មោះជាមនុស្សល្អប៉ុណ្ណោះ។ វាចង់ឱ្យគេសរសើរទាំងវា និងគ្រួសារវា។

វាបានយកលុយដែលឪវាយកពីនេះបន្តិច យកពីនោះបន្តិច មកធ្វើជាកម្មវិធី Charity ។ Charity មិនអាចចូលលុយតែវាបានទេ ហេតុនេះវាប្រកាសឱ្យមិត្តភក្តិវា និងអ្នកដែលមានបំណងចូលរួមដែរ ឱ្យបរិច្ចាកថវិកាខ្លះៗមក។

វាបានជួយប្រជាជនក្រីក្រតូចតាចបានច្រើននាក់ដែរ ហើយវាក៏បានខាងពតិមានចុះផ្សាយព្រោងព្រាត។ វានិយាយសរសើរពីឪវាដែលប្រឹងប្រែងធ្វើការ និងបង្រៀនវាឱ្យធ្វើជាមនុស្សល្អ។ មនុស្សជាច្រើន សរសើរវាហើយសង្ឃឹមថានឹងមានកូនដូចវាដែរ។

ប៉ុន្មានឆ្នាំក្រោយមក ឱកាសអួសកូនចូល ក៏មកដល់ ឪវាក៏យកវាចូលធ្វើការភ្លាម ទាន់ខ្លួននៅមានអំណាច។ វាក៏ធ្វើតាមទម្លាប់ឪវាទៅ ហើយវាដើរកុហកគេថា វាចូលដោយសារសមត្ថភាពវា តែតាមពិតវាមានសមត្ថភាពមែន។ វាមានសមត្ថភាពដូចឪវាដែរ គេបលុយយ៉ាងសាហាវ ហើយមានប្រពន្ធបាត់។

ក្រោយមកទៀត វាមានកូន ហើយកូនវាក៏ធ្វើតាមដានរបស់វាទៀត។ វិលចុះវិលឡើង គ្រួសារនេះងាកទៅខាងណាក៏ឃើញលុយដែរ។

១៧៤ - អួតផង អឿផង អាណាទ្រាំបាន?

១៧៥ - កុំជឿចិន កុំទុកចិត្តយួន កុំលះបង់ខ្លួន បម្រើបរទេស។

១៧៦ - ខ្ញុំរៀនបានចំណុចល្អច្រើនពីរឿងភាគចិន ហើយរៀនបានចំណុចអាក្រក់ច្រើនពីជនជាតិចិន។ អរគុណចិន។

១៧៧ - ខ្ញុំចូលចិត្តមើលរឿងចិន តែមិិនចូលចិត្តធ្វើការជាមួយជនជាតិចិនទេ ព្រោះពួកនេះ ទុកចិត្តមិនបាន ហើយស្គាល់តែខ្លួនឯងប៉ុណ្ណោះ។ បើអ្នកទាំងអស់គ្នាមានថៅកែចិន ប្រាកដជាយល់ពីរឿងនេះ។

ជួនកាល គេល្អនឹងយើងមែន ព្រោះគេគិតថា យើងទ្រពងវាបានល្អ តែវា

ធ្វើអាក្រក់ដាក់អ្នកផ្សេងទៀត។ មិនមែនទាល់តែគេធ្វើអាក្រក់ដាក់យើង បានយើងហៅគេថាមនុស្សអាក្រក់ទេ ។ ឱ្យតែធ្វើរឿងអាក្រក់ គឺអាក្រក់ហើយ មិនថាធ្វើដាក់អ្នកណាក៏ដោយ។

បើយើងរៀនតាមរឿងចិន យើងប្រហែលជាយល់ពីពាក្យគុណធម៌ខ្លះ តែបើរៀនតាមជនជាតិចិននៅក្រៅវិញ យើងស្គាល់តែពាក្យថាលុយមួយម៉ាត់ទេ ។ មិនមែនទេ នៅចេះផឹកស៊ី ចេះមានស្រីអីដែរ។

១៧៨ - ខំប្រាប់ថា គេបោកហើយ នៅឆ្លើយថា គេបោកអញមិនកើតទៀត ។

១៧៩ - ភ្លើបានន័យថា ដឹងការពិតហើយ ឃើញការពិតហើយ តែនៅបន្តជឿការកុហក។

១៨០ - យើងមិនក្លាយជាអ្នកប្រាជ្ញដោយសារតែមើលរឿងសាមកុកនោះទេ។

១៨១ - បើយើងមិនទាន់មុខរបរផ្ទាល់ខ្លួន ការមានការងារធ្វើ គឺជាការឈ្នះពាក់កណ្ដាលរបស់យើងហើយ។ យើងបានឈ្នះបញ្ហាអត់លុយចាយមួយ ហើយម្យ៉ាងទៀត បើយើងចាយសល់ យើងអាចនឹងសន្សំទុកប្រើពេលក្រោយទៀតបាន។

មានមុខរបររកស៊ីខ្លួនឯង ល្អជាង ធ្វើការឱ្យគេ។ ធ្វើការឱ្យគេ ល្អជាងដើរទាត់ខ្យល់ និងយកលុយម៉ែចាយ។ ដូច្នេះបើយើងមានការងារធ្វើ យើងនៅចំចំណុចកណ្ដាលតែម្ដង។ អ្នកដែលមិនទាន់មាន គួរតែសាកល្បងធ្វើទៅ។

បើមិនបានលុយច្រើន ក៏បានបទពិសោធន៍ពិតដែរ។

១៨២ - កូនអ្នកមានទៅរៀនសាលាថ្លៃៗ គេបង្រៀនពីរបៀបដាំកូនឈើ និងស្រលាញ់បរិស្ថាន។ ដល់ពេលពួកវាធំឡើង ឪម៉ែវាបង្រៀនឱ្យចេះកាប់ឈើ ទិញគ្រឿងសង្ហារឹមឈើថ្លៃៗ និងបញ្ចេញជាតិពុលចូលទៅធម្មជាតិ ហើយបើអាច បើកអាជីវកម្មណាដែលបំពុលមនុស្សឱ្យបានច្រើន។ បន្ទាប់មកមានកូន រួចបញ្ជូនកូនទៅរៀនសាលាថ្លៃៗ។

ខ្ញុំសរសេរខុសហើយ។ តែខ្ញុំមិនចង់លុបចោលទេ។

១៨៣ - អ្នកតូចរៀនធ្វើការយកមុខតាមអ្នកធំ។

## ខែមេសា ឆ្នាំ២០១៦

១៨៤ - គ្មានអ្នកណាដែលមានសំណាងអាក្រក់មួយជីវិតនោះទេ។

១៨៥ - បើគេប្រាប់ថា ជីវិតមនុស្សខ្លីណាស់ គ្មានអ្នកណាជឿទេ។ គេនាំគ្នាគិតថា គេអាចរស់បានប៉ុន្មានសិបឆ្នាំទៀត។ តែអ្នកណាទាយដឹងមុននោះ?

ដូច្នេះពេលនៅមានជីវិត យើងត្រូវរស់នៅឱ្យអស់ចិត្ត។ រស់នៅឱ្យអស់ចិត្ត គឺធ្វើរឿងដែលយើងចង់ធ្វើឱ្យហើយ និងកុំចំណាយពេលចោលច្រើនពេក។

បើគ្រាន់តែបើកមើលហ្វេសប៊ុក វាមិនទាន់ចាត់ទុកថា ជាការខ្ជះខ្ជាយពេលវេលាដ៏ធំនោះទេ តែបើទៅឆ្លើយ Comment មនុស្សភ្លើៗក្នុងហ្វេសប៊ុក ទើបជាការខ្ជះខ្ជាយ។ បើឈ្លោះជាមួយពួកវាដដែល ទុកពេលធ្វើអីផ្សេងវិញល្អជាង។ ខ្ញុំទើបតែរៀនពីចំណុចនេះក្នុងសៀវភៅ Steal Like an

Artist ។ ខ្ញុំធ្វើតាមពាក្យណែនាំក្នុងសៀវភៅម្តងបន្តិចៗ រហូតមកដល់ឥលូវបានសម្រេចហើយ ។

ខ្ញុំប្រើពាក្យភ្លើ អ៊ីចឹង មិនមែនបានន័យថា ខ្ញុំមើលងាយទេ តែខ្ញុំមិនដឹងប្រើ

ពាក្យអីទើបសម ។ គេខំបង្កើតហ្វេសប៊ុកដើម្បីឱ្យមនុស្សចេះចែករំលែកពតិមាន ឬចំណេះដឹង (និងកើបលុយទៅវិញដែរ) តែអ្នកខ្លះ មករកតែឈ្លោះគ្នា ។

១៨៦ - នៅក្នុងសង្គមមនុស្សពាល គ្មានពាក្យថាអានិតទេ ។

១៨៧ - បើអ្នកទាំងអស់គ្នាចង់រៀនតាមឆាវឆាវ ត្រូវរៀនធ្វើជាខ្លួនឯងពិតប្រាកដ ។ កុំដោរតាមគេ កុំខ្លាចគេថា ។ បើចង់បានអ្វី ត្រូវតែយកឱ្យបាន ។

ហើយសម្រាប់អ្នកដែលចូលចិត្តនិយាយថា រៀនតាមឆាវឆាវ គឺសុទ្ធតែជាមនុស្សអាក្រក់ ឬមនុស្សក្បត់ សូមមេត្តាបិទមាត់ ហើយបន្តធ្វើជាមនុស្សល្អទៀតចុះ ។ កុំចូលមក Comment នាំតែទើសគេអី ។

១៨៨ - កុំប្រដៅមនុស្សរឹង កុំខឹងមនុស្សចិត្តបិទ ។

១៨៩ - មនុស្សថោកទាប ចូលចិត្តធ្វើអ្វីជាងគេ? គឺចូលចិត្តនិយាយថាអ្នកដទៃជាមនុស្សថោកទាប ។

១៩០ - ដោយសារតែមនុស្សភាគច្រើន លេង Style តាមពួកអ្នកកាសែត ដោយកាត់យកសម្តីតែពាក់កណ្តាល ឬមួយផ្នែកដើម្បីបង្កើតជាពតិមានអត់ប្រយោជន៍ឱ្យបានច្រើន ។ មិនមែនអ្នកកាសែត ជាមនុស្សគ្មាន

ប្រយោជន៍ទេ តែខ្ញុំចង់ថា ការកាត់សម្ដីផ្នែក១យកទៅចុះផ្សាយបែបនេះ ជារឿងអត់ប្រយោជន៍។

១៩១ - បើមិនអានសិន ម៉េចនឹងដឹងថាគេសរសេរពីអី។

១៩២ - ទម្លាប់របស់ខ្ញុំ ឱ្យតែមានអ្នកណា post ថានយោបាយជារឿងត្រឹមត្រូវ ឬថាអ្នកដែលរៀនមិនដល់ទើបមិនយល់ពីនយោបាយ ថែមទាំងចោតថាអ្នកនយោបាយបោក ខ្ញុំunfriend ចោលភ្លាម។ បើនៅលើ Page វិញ ban ចោលភ្លាម។ ព្រោះអី?

មនុស្សគំនិតខុសគ្នា មិនលេងហ្វេសប៊ុកជាមួយគ្នាទេ។

១៩៣ - សូម្បីតែមុខក្រាស់ ក៏មានគេសរសើរដែរ តែគេសរសើររបៀបឌឺទេ។

១៩៤ - សូម្បីតែនិយាយ ក៏ស៊ីម៉ាអ៊ីគាត់ទុកផ្លូវក្រោយដែរ។ ចាញ់ល្បិចជូកីលាងតែម្ដង រាងចាលមួយជីវិត។

១៩៥ - ចិត្តបាប និងចិត្តផ្ដេសផ្ដាស ខុសគ្នាយ៉ាងម៉េចទៅ? ខ្ញុំគិតថា ចិត្តផ្ដេសផ្ដាស ជាដើមហេតុដែលបង្ករឱ្យមានចិត្តបាប។ ចិត្តបាប គ្រាន់តែជាផលដែលអាចកើតពីចិត្តផ្សេងៗទៀតប៉ុណ្ណោះ។

១៩៦ - សុខចិត្តឱ្យគេថាឆ្កួត ប្រសើរជាងគេថាភ្លើ។

១៩៧ - ថ្ងៃនេះ ខ្ញុំរៀនចេះរឿងមួយដ៏សំខាន់ គឺ ការវាយតម្លៃសៀវភៅ។ នៅពេលយើងវាយតម្លៃសៀវភៅ ឬ ជាភាសាអង់គ្លេសហៅថា Rate គួរ

តែជ្រើសរាំងការឱ្យផ្កាយមួយទៅលើសៀវភៅ។ ហេតុអី?

- ទីមួយ ព្រោះថា សៀវភៅមួយក្បាល ជាការប្រឹងប្រែងរបស់មនុស្សម្នាក់ជួនកាលអាចចំណាយពេលរាប់ឆ្នាំទៀតផង។ ហេតុនេះបើឱ្យផ្កាយមួយដូចជាមិនសម។

- ទីពីរ ព្រោះថា ការឱ្យផ្កាយមួយនឹងក្លាយជាអ្នកបញ្ចប់អាជីពនិពន្ធរបស់មនុស្សម្នាក់តែម្តង។ បើអាចជ្រើសបាន យើងគួរតែទុកផ្លូវឱ្យគេដើរខ្លះផង។

- ទីបី ព្រោះថា វាធ្វើឱ្យយើងក្លាយជាមនុស្សដែលមិនចេះមើលចំណុចល្អ។ សៀវភៅដែលមានចំណុចល្អតែ២ ឬ៣ ប៉ុណ្ណោះ ក៏អាចចាត់ទុកជាសៀវភៅល្អបានដែរ។

អ៊ីចឹង តើគួរឱ្យផ្កាយប៉ុន្មាន? ផ្កាយ៣ ល្អបំផុត ព្រោះបានន័យថា យើងនៅចន្លោះកណ្តាលការពេញចិត្ត និងមិនពេញចិត្ត។ តែបើយើងមិនសូវជាមានចិត្តល្អ ឱ្យផ្កាយពីរក៏បានដែរ។

១៩៨ - សម្រាប់អ្នកដែលមិនទាន់បានមើល គួរតែរកពេលទំនេរមើលរឿងសាមកុកទៅ។ វាមិនខាតទេ គ្រាន់តែមើលរឿងមួយឱ្យចប់នោះ។

១៩៩ - ខ្មែរខ្លះស្អប់យួន តែស្រលាញ់ថៃ។ ថៃ និងយួន វាទៅណាគ្នា?

២០០ - សុភាសិតខ្មែរ មានន័យល្អម្យ៉ាង។ សុភាសិនចិន មានន័យល្អម្យ៉ាងទៀត។ សុភាសិតខាងពួកអាមេរិច ក៏ទំនង។ ខ្ញុំដូចមិនដែលបានអានសុភាសិតយួនសោះ។ អស់ខ្លួនជាតិនេះ ជាតិក្រោយបានដីនៅស្រួល។

២០១ - តើភាពលោភលន់ នាំឱ្យមានផលអាក្រក់អ្វីខ្លះ?

-រមិលគុណ ៖លីពូសម្លាប់ឪពុកធម៌ខ្លួនឯង ព្រោះតែលោភលន់ទ្រព្យសម្បត្តិ និងសេះទន្សាយក្រហមដែលតុងជួយកមកឱ្យ ។

-បាត់បង់ការគិតពីលទ្ធផល ៖ឆាយម៉ាវលោភលន់នឹងតំណែងដែលឆាវឆាវសន្យាថាផ្តល់ឱ្យ ក៏បានលក់ម្ចាស់តូច ឆាវឆុង ឱ្យចុះចូលនឹងរាជការ ។

-នាំទុក្ខដាក់ខ្លួន ៖យានស៊ូ លោភលន់អំណាច ប្រកាសខ្លួនជាស្តេច នាំឱ្យសម្តេចដទៃទៀតច្រណែន ហើយត្រូវមានឈ្មោះជាចោរក្បត់ជាតិ ចុុងក្រោយត្រូវស្លាប់ ។

២០២ - តាមពិតរឿងថៃ គេមានចំណុចពិសេសរបស់គេមួយ ដែលយើងគ្រប់គ្នាដែលមិនចូលចិត្តរឿងថៃបានដឹងយូរណាស់មកហើយ គឺ ការដណ្តើមប្រុសគ្នា ។ តែសម្រាប់អ្នកដែលចូលចិត្តមើលរឿងថៃ គេនិយាយថារឿងថៃបង្រៀនគេច្រើនណាស់ ។

ខ្ញុំមិនសូវជាចាប់អារម្មណ៍រឿងថៃប៉ុន្មានទេ ព្រោះខ្ញុំគិតថា សាច់រឿងនៅតែមួយប្រឡោះហ្នឹង យ៉ាងច្រើនណាស់ ប្តូរក្បាលបន្តិច និងចុងបន្តិចប៉ុណ្ណោះ តែតួរឿង គឺស្រីដណ្តើមប្រុសគ្នា ហើយប្រុសដណ្តើមទ្រព្យគ្នា ។

យើងមិនអាចថា រឿងថៃ ថតមិនល្អមើលបានទេ ព្រោះតួកុនគេស្អាតៗ ។ តួកុនស្អាត ក៏ជាផ្នែកមួយនៃភាពយន្តដែរ ។ បើរឿងថៃបែបកំប្លែងខ្ញុំមើលចូល តែបើបែបស្នេហាវិញ ទៅមិនរួចទេ ។

២០៣ - " មិនធ្វើការ សន្សំរឿង ទុករឿងអ្នកដទៃក្នុងខ្លួនឯងច្រើនពេក ធ្វើឱ្យសេចក្ដីសុខខ្លួនឯងបាត់បង់ព្រោះរវល់តែខ្វល់ខ្វាយពីគេ " ។

នេះជាសម្ដីរបស់ ភិន សុដាលីស ។ ខ្ញុំមិនដែលខ្វល់នឹងរឿងរបស់តារាទេ តែដោយសារខ្ញុំឃើញចំណងជើងដែលគេសរសេរមកថា ភិន សុដាលីសថាឱ្យអ្នកដែលរិះគន់នាង ខ្ញុំក៏ចុចអានភ្លាម។ ដឹងស្រាប់ហើយ ឱ្យតែមានគេប្រឆាំងនឹងការរិះគន់ ខ្ញុំដឹងថាគាំទ្រហើយ ។

គេសម្រេចចិត្តស្រលាញ់អ្នកណាជារឿងគេសោះ ម្នាក់ៗធ្វើឯងចេះដឹងណាស់ សុទ្ធតែទៅប្រដៅគេទៀត មិនដឹងជាស្គាល់គេតាំងពីកាលណាទេ ។

ភិន សុដាលីស នៅមានមួយឃ្លាទៀត ដែលស្រដៀងនឹងអ្វីដែលខ្ញុំធ្លាប់និយាយដែរ ។

" រឿងជីវិត គេៗអាចដោះស្រាយបានដោយខ្លួនគេ អ្នកមិនចាំបាច់ជាន់ពន្លិច ឬចេះដឹងរឿងគេនោះទេ គួរតែទុកពេលវេលាទាំងនោះសម្រាប់ខ្លួនឯង ធ្វើអ្វីដែលធ្វើឱ្យខ្លួនឯង សប្បាយចិត្ត ហើយមិនរំខានជីវិតឯកជនរបស់អ្នកដទៃ " ។

សម័យនេះ មនុស្សចេះដឹងច្រើនណាស់ ហើយកាន់តែចេះដឹងទៀត បើទាក់ទងនឹងរឿងរបស់អ្នកដទៃ។ ឧទាហរណ៍ អាមួយអីដែលល្បីជាងគេលើហ្វេសប៊ុក មួយរយៈនេះ។

ខ្ញុំមិនមែនជាអ្នកគាំទ្រ ភិន សុដាលីសទេ តែខ្ញុំគាំទ្រចំពោះការប្រឆាំងនឹងពាក្យរិះគន់របស់អ្នកដទៃ។ យើងមិនមែនកើតមកដើម្បីធ្វើតាមពាក្យរិះ

គន់របស់គេទេ តែយើងកើតមកដើម្បីធ្វើកិច្ចការដែលយើងគិតថាត្រូវធ្វើ និងធ្វើហើយបានភាពរីករាយមកវិញ។

២០៤ - កាលពីជំនាន់ស្តេចជ័យវរ័្មនទី៧ អត់មានក្រសួងសុខាភិបាលទេ តែមានក្រសួងរោគាភិបាល។ ក្រសួងនេះចែកទាំងស្បៀង និងថ្នាំពេទ្យដល់ប្រជារាស្ត្រ។ ស្តេចជ័យវរ័្មនទី៧ សង់រោងព្យាបាលរហូតដល់ទៅ១០២ កន្លែងដើម្បីជួយរាស្ត្រ។ គេសរសេរថា ជម្ងឺរបស់រាស្ត្រធ្វើឱ្យព្រះអង្គឈឺចាប់ជាជម្ងឺខ្លួនឯងទៅទៀត។

ឥលូវខ្ញុំលែងឆ្ងល់ហើយថា ហេតុអ្វីបានជាគេនាំគ្នាលើកស្តេចជ័យវរ័្មនទី៧ខ្លាំងម្លេះ? ព្រោះបើគ្រាន់តែពូកែច្បាំង មានមិនខ្វះទេ ស្តេចខ្មែរ តែស្តេចដែលខ្វល់ខ្វាយពីរាស្ត្រ មានមិនច្រើនទេ។

២០៥ - កុំព្យាយាមប្រដៅអ្នកដទៃនៅកណ្តាលចំណោមមនុស្សច្រើន ។

២០៦ - នៅពេលដែលមនុស្សមើលរឿង hero ច្រើនពេក ឱ្យតែមានអ្នកណាធ្វើអ្វីយកមុខបន្តិច ក៏នាំគ្នាហៅគេថា hero។ ដល់ពេលភ្ញាក់ខ្លួនថាគិតខុស ក៏នាំគ្នាជេរគេវិញ។

ក្នុងពេលថ្មីៗនេះ ខ្ញុំទើបតែមាន hero ថ្មីមួយ ឈ្មោះថា Deadpool។ ក្រៅពីនេះ ខ្ញុំមិនស្គាល់ទេ ចង់ពាក់អាវធំម៉ូតក៏ដោយ និយាយអួតពីអីក៏ដោយ ក៏ខ្ញុំមិនខ្វល់។

២០៧ - ស្អប់ដល់ហើយ អាអ្នក Post Status ផ្សេង ដល់ពេលនៅក្រៅធ្វើផ្សេងហ្នឹង។ ខ្ញុំសង្ឃឹមថា អ្នកដែល Like Page នេះទាំងអស់ កុំធ្វើបែប

នេះ ព្រោះវាជារឿងអាក្រក់។ វាធ្វើឱ្យយើងក្លាយជាមនុស្សអាក្រក់ដោយមិនដឹងខ្លួន។

ខ្ញុំចូលចិត្តPost អ្វីដែលខ្ញុំធ្វើបាននៅក្រៅ។ ដូចជា បើខ្ញុំចូលចិត្តរឿងសាមកុក ខ្ញុំមើលរឿងផង អានសៀវភៅរឿងផង ធ្វើ Page សាមកុកផង ហើយសរសេរសៀវភៅខ្លួនឯងទៀត ព្រោះខ្ញុំចូលចិត្តរឿងហ្នឹងមែន។ ហើយខ្ញុំបើខ្ញុំប្រាប់ស្អប់ដែលចេះត្រឹមតែរិះគន់ គឺខ្ញុំBlock ចោលភ្លាម កុំឱ្យពួកវាមកធ្វើឱ្យខូចអារម្មណ៍ខ្ញុំ។

អ៊ីចឹងហើយបានជា Page ខ្ញុំគ្មានអ្នក Like។

២០៨ - អ្នកដែលមើលរឿងសាមកុក កុំរៀនប្រើសម្ដីតាមជូកឺលាង ព្រោះសម្ដីភាគច្រើនរបស់ជូកឺលាង ច្រើនជាពាក្យមើលងាយអ្នកដទៃ តែដោយសារ គាត់ជាតួអង្គគាំទ្ររាជវង្សហាន ទើបយើងមិនសូវជាចាប់អារម្មណ៍។ ម្យ៉ាងជូកឺលាង មានប្រាជ្ញាជាងអ្នកដទៃ ហេតុនេះសម្ដីដែលគាត់និយាយ ទោះបីជាបន្ថោកតម្លៃអ្នកដទៃដល់កម្រិតណា ក៏គ្មានបញ្ហាដែរ។

តែយើងខុសគ្នា បើយើងទៅនិយាយជាមួយគេ ប្រើពាក្យថា មនុស្សល្ងង់ ឬ ខួរក្បាលស្ពឹក វិញ គេនឹងអន់ចិត្តជាមួយយើងភ្លាម។ យើងអាចទស្សនៈ ឬវិធីសាស្ត្រដោះស្រាយបញ្ហារបស់ជូកឺលៀងមករៀនតាមបាន តែកុំប្រើសម្ដីដូចគាត់។

បើមិនជឿទេ ចាំមើលអ្នក Comment តាម Style ជូកឺលាងទៅ ឃើញហើយ។ ចេញមកដូចមានតែឯងបានមើលរឿងសាមកុក។

## ខែមិនា ឆ្នាំ២០១៦

២០៩ - តើយើងរៀនអ្វីខ្លះ នៅពេលធ្វើការ?

- រៀនពីបុគ្គលិកដទៃទៀត ថាតើគេធ្វើការរបៀបម៉េច? បើចំណុចណាល្អ ធ្វើការទៅបានប្រសិទ្ធិភាព យើងធ្វើតាមគេភ្លាម។ បើចំណុចអាក្រក់ ធ្វើជាមើលមិនឃើញចុះ។

- រៀនពីការធ្វើទំនាក់ទំនងពិតប្រាកដ។ វាខុសពីក្នុងថ្នាក់រៀន ដែលយើងត្រូវបង្ខំចិត្តធ្វើក្រុមជាមួយអ្នកដែលយើងមិនស្គាល់ ឬមិនចូលចិត្ត។ នៅក្នុងការងារ ទំនាក់ទំនង ជារឿងសំខាន់។ ការងារយឺត ឬលឿន ក៏ព្រោះតែទំនាក់ទំនងនេះដែរ។

- រៀនពីថ្នាក់លើរបស់យើង។ យើងត្រូវលួចមើលថា គេធ្វើម៉េចបានជាមានឱកាសធ្វើថ្នាក់លើយើង ឬបើកក្រុមហ៊ុនខ្លួនឯងបែបនេះ។ យើងត្រូវរៀនពីអ្នកដែលយើងចង់បានដូចគេ។

-រៀនពីកំហុស។ ពេលធ្វើការ ជៀសមិនផុតទេ ពីការធ្វើខុស ដូច្នេះរាល់ពេលខុសម្តង ត្រូវចំណាំវាទុក កុំឱ្យខុសម្តងទៀត។ ការខុសច្រើនដង តែកំហុសប្លែកៗគ្នា នឹងធ្វើឱ្យយើងដឹងកាន់តែច្រើន។ បើសិនការងារដែលយើងធ្វើនោះ មិនមានអ្វីដែលយើងអាចធ្វើខុស បានន័យថា យើងធ្វើការងាប់ក្រឡាហើយ គ្មានចេះអ្វីថ្មីទេ។

- រៀនពីឧបសគ្គ។ ពេលធ្វើការ យើងអាចនឹងជួបអ្វីថ្មីដែលដោះស្រាយមិនចេញ នោះហើយជាពេលរៀនបន្ថែម។ សម័យនេះស្រួលណាស់ Google

តែមួយភ្លែតនឹងបានឯកសារអានហើយ។ បើយើងយកម៉ោងធ្វើការទៅរៀនអ្វីថ្មីតែម្តង ថ្នាក់លើយើងនឹងគិតថា យើងជាមនុស្សកេងប្រវ័ញ្ចពេលវេលា តែបើយើងយកឧបសគ្គ ដើម្បីធ្វើលេសរៀនអ្វីថ្មី គ្មានអ្នកណាមកបន្ទោសយើងទេ។

- រៀនពីក្រុមហ៊ុន។ ចំពោះចំណុចនេះ មានតែក្រុមហ៊ុនតូចៗទេ ទើបមាន។ ពេលយើងធ្វើការក្នុងក្រុមហ៊ុនតូច យើងនឹងមានឱកាសរីកចម្រើនតាមក្រុមហ៊ុន។ បើក្រុមហ៊ុនដំណើរការទៅមុខ យើងនឹងស្គាល់កាន់តែច្រើន តែបើវាមិនដំណើរការ ឬបរាជ័យ យើងក៏នៅតែរៀនបានដែរ។ ក្រុមហ៊ុនតូច ជាឱកាសក្នុងការរៀនសូត្រ តែកុំរំពឹងថាប្រាក់ខែច្រើន។

សម្រាប់អ្នកដែលមិនធ្លាប់ធ្វើការ ឬធ្លាប់ធ្វើការលេងៗ (ស្ម័គ្រចិត្តប្រភេតយកមុខមាត់) គេមានវិធីគិតបែបផ្សេងពីអ្នកដែលធ្លាប់ធ្វើការ។ ខ្ញុំសំណាងណាស់ ដែលខ្ញុំមិនជឿអ្នកដទៃដែលប្រាប់ឱ្យខ្ញុំទៅធ្វើការស្ម័គ្រចិត្តដើម្បីយកបទពិសោធន៍។ បើជ្រុលតែធ្វើយកបទពិសោធន៍ហើយ ធ្វើមែនទែនតែម្តងទៅ ។ ខ្ញុំមិនចូលចិត្តទេ ពាក្យថា បុគ្គលិកស្ម័គ្រចិត្តនេះ ព្រោះមានអារម្មណ៍ ថាត្រូវគេបោកក្បាលប្រើ។

ខ្ញុំធ្វើការជិត៥ឆ្នាំ ហើយ តាំងពីខ្ញុំចូលរៀនសាកលដំបូងម្ល៉េះ។ ខ្ញុំរៀនចេះរឿងមួយ គឺ" ឱ្យតែមានជំនាញ យើងនឹងក្លាយជាមនុស្សមានប្រយោជន៍ហើយ" ។ ខ្ញុំប្រឹងធ្វើយ៉ាងណាឱ្យខ្លួនឯងមានជំនាញ មួយ ឬពីរច្បាស់លាស់ចំណែកអារឿង អែបអប និងទ្រពង ចាំគិតតាមក្រោយទៀត ព្រោះអា

ហ្នឹងមិនសូវសំខាន់។ មិនមែនថាវាមិនសំខាន់ទេ គ្រាន់តែវាសំខាន់តាមក្រោយ។

មិនបាច់ទៅមើលអីឆ្ងាយទេ សាកប្រៀបធៀប អ្នករត់ម៉ូតូឌុប និងអ្នកប្រណាំងម៉ូតូអាជីពទៅដឹងហើយ។ ជិះម៉ូតូដូចគ្នា ហេតុអីមួយត្រូវគេឱ្យតម្លៃ ឯមួយទៀតត្រូវគេមើលរំលង។ គឺដោយសារតែពាក្យ ជំនាញហ្នឹងឯង។

២១០ - កាលពីខ្ញុំនៅក្មេង ខ្ញុំគិតថាអ្នកដែលបានរៀន ពាក់ខោអាវនិស្សិតពណ៌ខៀវ មើលទៅអស្ចារ្យណាស់ តែដល់ពេលឥលូវ ទើបខ្ញុំដឹងថា ភាពអស្ចារ្យ មិននៅលើខោអាវនិស្សិតហ្នឹងទេ។ អ្នកខ្លះមិនបានរៀនផង តែចេះយល់ការរាក់ជ្រៅ ស្គាល់កាលៈទេសៈ និងចេះរកលុយបានល្អជាងអ្នកស្លៀកពាក់ស្អាតបាតនោះទៀត។

នៅក្នុងសង្គមខ្មែរយើង សម្បូរណាស់ រូបភាពនិយម ។ ឱ្យតែមិនប្រយ័ត្ននឹងចាញ់បោកគេភ្លាម។

២១១ - នៅពេលដែលមានឱកាសរៀន ត្រូវតែរៀន នៅពេលឱកាសការងារមកដល់ ត្រូវតែធ្វើការ។ អ្នកខ្លះមិនហ៊ានចោលរៀន ទៅធ្វើការទេ ខ្លាចអត់សញ្ញាប័ត្រ ដល់ពេលរៀនចប់ចេញមក គ្មានអ្នកណាយក ព្រោះគ្មានបទពិសោធន៍។ តែយើងត្រូវមើលការងារដែរ ថាវាអាចជួយយើងឱ្យទៅមុខទៀត ឬនៅមួយកន្លែង។

ក្រែងយើងរៀនដើម្បីធ្វើការរកលុយអី ?

២១២ - អំណាច និងចិត្តធម៌ មានសារៈសំខាន់ណាស់សម្រាប់អ្នកដឹកនាំគ្រប់រូប។ ឆាវឆាវ ជាគម្រូល្អមួយ សម្រាប់អ្នកដឹកនាំគ្រប់រូប តែយើងក៏អាចយកតម្រាប់តាមបានដែរ ព្រោះក្រែងលោថ្ងៃក្រោយទៅ បានដឹកនាំនឹងគេ។ ខ្ញុំនិយាយឡើងវិញដដែលៗ ថា “អំណាច មិនអាក្រក់ទេ បើយើងមិនប្រើវាក្នុងផ្លូវអាក្រក់ អំណាច មិនធ្វើឱ្យមនុស្សក្លាយជាអាក្រក់ គឺមនុស្សទេដែលធ្វើខ្លួនឯងឱ្យអាក្រក់។”

២១៣ - បើយើងមើលងាយអ្នកដទៃពេក យើងនឹងនាំគ្រោះថ្នាក់មកដល់ខ្លួនឯងមិនខាន។

យានសាវ នឹកស្មានថា ឆាវឆាវមិនហ៊ានច្បាំង ក៏យល់ព្រមចរចារនឹងឆាវឆាវ ហើយចុងក្រោយចាញ់ល្បិចពន្យាពេលរបស់ឆាវឆាវទៅ។ នៅក្នុងវគ្គនេះ ឆាវឆាវបានបញ្ជាក់ថា ឱ្យតែខ្លួននៅមានដង្ហើម ខ្លួនគាត់នៅតែអាចរកផ្លូវច្បាំងឈ្នះរហូត។

២១៤ - នៅក្នុងការរស់នៅ មានរឿងសំខាន់ និងរឿងសំខាន់ជាង។ អាសំខាន់ជាង យើងត្រូវធ្វើមុន ហើយចាំមកធ្វើអាសំខាន់ម្តង។ ឧបមាថា យើងឈឺជុះ តែយើងត្រូវជិះម៉ូតូទៅក្រៅដើម្បីទិញចំណី តើមួយណាសំខាន់ជាង? ច្បាស់ជាជុះឱ្យអស់សិនហើយ។

យើងមិនមែនកើតមកដើម្បីស៊ី និងជុះទេ តើបើយករឿង ជុះ និងស៊ី មកប្រៀបធៀបគ្នា ជុ◌ុ◌ះវាបន្ទាន់ជាងស៊ីហើយ។

២១៥ - "មនុស្សដែលរៀនចេះក្បួនសឹកនោះ សុទ្ធតែជាមនុស្សល្ងង់"

តើសម្ដីនេះមានន័យថាម៉េច?

ឆាវយិនចូលមកនិយាយពីក្បួនសឹកជាមួយនឹងឆាវឆាវ ក៏ត្រូវឆាវឆាវស្ដីឱ្យថាមិនចេះគិតគូរ។ ឆាវយិន ជឿលើក្បួនសឹកខ្លាំងពេក ហើយនៅជឿទៀតថា ខាងសត្រូវនឹងធ្វើតាមក្បួនសឹកដូចខ្លួនឯង។

ក្បួនសឹក ជាតំណាងដល់ចំណេះវិជ្ជា។ អ្នកដែលមានតែចំណេះវិជ្ជា តែមិនចេះប្រើឱ្យត្រូវតាមពេលវេលា ក៏មិនខុសអីពីអ្នកដែលមិនបានរៀនសូត្រដែរ។ ចំណេះវិជ្ជា ត្រូវការភាពបត់បែន ការវិវឌ្ឍខ្លួនទៅមុខ និងការលាយបញ្ចូលគ្នា។ គ្មានអ្នកណាប្រើចំណេះវិជ្ជាដោយត្រង់គ្រប់កន្លែងនោះទេ។

ឧបមាថា ឆាវឆាវ លើកទ័ពទៅវាយលីវប៊ុអ៊ុចឹង។ បើតាមក្បួនសឹក ឆាវឆាវលើកទ័ពមក គួរតែធ្វើសង្គ្រាមរហ័ស ដើម្បីកុំឱ្យមានបញ្ហាស្បៀង និងចំណាយទ្រព្យរដ្ឋច្រើន តែឆាវឆាវវាយបានពាក់កណ្ដាល ក៏ដកថយ ដោយមិនយកខ្មោចទាហានរបស់ខ្លួនទៅតាមទៀត។

ចំណែកលីវប៊ុ ឃើញខ្មោចកងទ័ពឆាវឆាវនៅពេញដីយ៉ាងច្រើន ក៏គិតថាឆាវឆាវចាញ់ហើយ ក៏រៀបចំទ័ពទៅវាយបន្ទាយធំ ដល់ចុងក្រោយក៏ចូលល្បិចរបស់ឆាវឆាវ ត្រូវវិនាសកងទ័ពទាំងអស់។

លីវប៊ុ ចេះក្បួនសឹក តែមិនដឹងប្រើយ៉ាងណា ទើបមិនអាចចាត់ការឆាវឆាវបាន និងចេះតែត្រូវបរាជ័យក្រោមដៃឆាវឆាវជានិច្ច។ ក្បួនសឹកក៏ដោយ ចំណេះដឹងក៏ដោយ ត្រូវដឹងរបៀបប្រើជាមុនសិន ទើបយកទៅប្រើបានផលល្អ។

២១៦ - ធ្វើដូចខ្ញុំទៅ អាណាគេចូលចិត្តធ្វើការយកមុខ ទុកឱ្យវាយកមុខតែឯងចុះ កុំរវល់ កុំរាប់រក តែពេលណាវាធ្វើអត់ចេញ វាគង់តែអស់អីនិយាយដោយខ្លួនឯងទេ។ បើយើងទៅឈ្លោះនឹងវា បានន័យថា យើងក៏ជាមនុស្សយកមុខដែរហើយ។ នេះជារបៀបធ្វើការនៅក្នុងក្រុមហ៊ុនរបស់ខ្ញុំ។

២១៧ - ថ្ងៃនេះជាទិវាជាតិអំណាន។ ខ្ញុំឆ្ងល់ដែរ ម៉េចគេមិនដាក់ទិវាអានសៀវភៅ ឬទិវាអ្នកអាន អីវិញ? វាស្រួលស្តាប់បន្តិច។ ទិវានេះគេធ្វើឡើងដើម្បីលើកកំពស់ការអាន ហើយនេះជាលើកទីមួ្ួយនៃទិវានេះដែរ។

ខ្ញុំនិយាយតាមត្រង់ អានសៀវភៅ មិនបាច់មានទិវាទេ ចង់អាន យកមកអានមក បើមិនចង់អាន កុំអានទៅបានហើយ។ ខាងក្រសួងគិតថា ធ្វើបែបនេះ អាចនឹងលើកតម្កើងការអានសៀវភៅនៅក្នុងស្រុកយើងបាន។ ខ្ញុំមិនសូវជឿសោះ។

២១៨ - កាលនៅតូច ចូលចិត្តមើលកីឡាកាស ដល់ធំឡើងចូលចិត្តមើលគេសម្ភាសអ្នកកីឡាកាស។ បើទំនេរស្តាប់ការសម្ភាសរបស់ CM Punk ទៅ។ នៅក្នុងការសម្តែង គាត់ជាមនុស្សខូចទេ តែនៅក្រៅ គាត់ជាមនុស្សឆ្លាតម្នាក់។

២១៩ - បើជ្រុលជាសរសើរគេហើយ កុំស្តាយ។

២២០ - ខ្ញុំទើបឃើញពតិមានដែលគេសរសេរថា ប៉ែនចំរុងជិតក្លាយជាឪពុកគេហើយ។ ខ្ញុំមិនខ្វល់ថា ប៉ែនចំរុងមានកូន ឬអត់នោះទេ អ្វីដែលសំខាន់ គឺ ទន្សាយខ្ញុំជិតកើតកូនហើយ។ វាកំពុងតែរៀបចំសំបុកវាពីព្រឹក

មិញនេះ។ កើតលឿនពេក អាណាវៀបកន្លែងឱ្យវាទាន់លោក។

**ខែកុម្ភៈ ឆ្នាំ២០១៦**

២២១ - ពេលបម្រើមនុស្សអាក្រក់ កុំរំពឹងចង់បានរង្វាន់។ ទាយទៅមើល ថា ខ្ញុំដកស្រង់ឃ្លានេះចេញមកពីសៀវភៅណា?

២២២ - សួស្តីអ្នកទាំងអស់។ ខ្ញុំមានរឿង ៣ ចង់ប្រាប់។

ទីមួយ គឺ កុំហៅខ្ញុំថា Admin ទៀត ព្រោះខ្ញុំមិនចូលចិត្តពាក្យនេះទេ។ អ្នកទាំងអស់គ្នា អាចហៅខ្ញុំថា បង ក៏បាន ប្អូនក៏បាន តែហៅបងទៅ ព្រោះខ្ញុំក៏អាយុច្រើនដែរ សក់ខ្ញុំឡើងស្កូវខ្លះទៅហើយ។

ឬបើចង់ហៅឈ្មោះខ្ញុំក៏បានដែរ។ ខ្ញុំឈ្មោះ ហួត សេងគៀ។ អ្នកទាំងអស់គ្នាប្រាកដជាឆ្ងល់ថា ឈ្មោះផ្សេងម៉េចមិនដាក់ តែមិនបាច់ឆ្ងល់ទេ ព្រោះនេះជាការសម្រេចចិត្តរបស់ម៉ែឪខ្ញុំ មិនអាចកែបានទេ។ កុំហៅត្រកូលខ្ញុំក៏បានដែរ ព្រោះស្តាប់ទៅទើសត្រចៀកណាស់។

បើអ្នកណាសួរខ្ញុំ ហើយហៅខ្ញុំថា Admin ខ្ញុំអត់ Reply ទៅវិញទេ ។ ខ្ញុំធ្វើ page នេះយូរហើយ មិនដែលហ៊ានហៅខ្លួនឯងថា Admin ផង។

ទីពីរ គឺ Page នេះអត់មានក្រុមទេ។ ខ្ញុំធ្វើតែម្នាក់ឯងប៉ុណ្ណោះ។ កាលពីមុន ខ្ញុំកុហកគេថា ធ្វើជាក្រុម ព្រោះមិនចង់បដិសេធគេ ពេលគេសូមជួយធ្វើ។ ខ្ញុំចង់មានអ្វីជារបស់ផ្ទាល់ខ្លួន មិនចង់ឱ្យអ្នកណាមកលូកលាន់ទេ។ ខ្ញុំដឹងថា ការធ្វើជាក្រុម វាបានផលល្អជាង តែនេះជាចរិតខ្ញុំ ក៏មិនអាចកែបានដែរ។

ទីបី គឺ Page នេះមិនមែនបង្កើតឡើងដើម្បីអួតទេ ដូច្នេះរាល់អ្វីដែលខ្ញុំ Post គ្មានបំណងអីទាំងអស់។ ខ្ញុំអត់ដឹងមែនថា ហេតុអ្វី ខ្ញុំនៅតែបន្តធ្វើ Pageនេះ។ វាអាចជាទម្លាប់មួយ ព្រោះខ្ញុំធ្វើ ជិត 3 ឆ្នាំមកហើយ។

បើគិតថា អ្វីដែលខ្ញុំ Post ជាការអួត កុំអានអី។ ខ្ញុំគ្មានរឿងអីត្រូវអួតជាមួយមនុស្សមិនដែលស្គាល់គ្នានោះទេ។ មនុស្សតែម្នាក់ដែលខ្ញុំអួតដាក់ គឺ សង្សារខ្ញុំ ក្រៅពីនេះ អ្នកណាចង់ធ្វើអី ធ្វើទៅ ខ្ញុំអត់ខ្វល់ទេ។

មិនមែនតែខ្ញុំទេ អ្នកទាំងអស់គ្នាដែលធ្លាប់ចូល Comment នៅក្នុង Page ក៏មិនត្រូវអួតដែរ។ យើងអាចបញ្ចេញយោបល់ តែកុំបង្កប់ការអួតក្នុងហ្នឹង ហើយមួយទៀត កុំឧស្សាហ៍ ប្រើពាក្យល្ងង់នៅក្នុង Comment ពេក ព្រោះបើធ្វើបែបនេះ វាដូចជាយើងគិតថាខ្លួនឯងឆ្លាតពេក។ បើថា តួណាមួយក្នុងរឿងជាមនុស្សល្ងង់ អាហ្នឹងមិនអីទេ ព្រោះតួអស់ហ្នឹង អត់ដឹងថាយើងនិយាយអី។

សុំថែមមួយរឿងទៀត ។ ខ្ញុំមានចរិតពីរ មួយល្អ មួយអាក្រក់។ ពេលដែលខ្ញុំអង្គុយសង្ខេបរឿងពីក្នុងសៀវភៅ ជាចរិតល្អរបស់ខ្ញុំ ព្រោះខ្ញុំចង់អ្នកផ្សេងទៀតបានដឹងដែរ។ តែពេលដែលអ្នកណាសរសេរអីមិនល្អ ប៉ះពាល់ដល់ខ្ញុំ ខ្ញុំក៏បញ្ចេញចរិតអាក្រក់ទៅវិញភ្លាម។

ដូច្នេះ បើសិនជាឃើញខ្ញុំសរសេរអ្វីដែលមើលទៅដូចជាខឹង កុំប្រកាន់ខ្ញុំអី តែបើចង់ប្រកាន់ ក៏ប្រកាន់ទៅ ខ្ញុំក៏មិនដឹងធ្វើយ៉ាងម៉េចដែរ។

២២៣ - ចែកអំណោយមិនអស្ចារ្យ អ្នកចូលជួយក្នុងភ្លើងទើបអស្ចារ្យ។

២២៤ - បើថាខ្លាំងណាស់ ទៅធ្វើជាអ្នកនយោបាយទៅ កុំចំណាយពេលអត់ប្រយោជន៍ជាមួយ Page ខ្ញុំ ។ Page ខ្ញុំគ្មានប្រយោជន៍អីដល់នយោបាយទេ តែមានប្រយោជន៍ដល់អ្នកដែលចូលចិត្តរឿងសាមកុក ។ ពេលខ្លះ ខ្ញុំក៏និយាយពីការអានសៀវភៅដែរ ដើម្បីកុំឱ្យខ្មែរភ្លេចការអាន។ យី! ខ្ញុំដូចជាមិនដែលលឺអ្នកនយោបាយខ្មែរ ទូន្មានឱ្យប្រជាជនចេះអានសៀវភៅសោះ? អូ ខ្ញុំដឹងហើយ ព្រោះបើប្រជាជនចេះខ្លាំងពេក ពិបាកបោក។

២២៥ - គ្រាន់តែមិនលក់ដីឱ្យយួន ក៏គេហៅថាស្នេហាជាតិដែរ។ អ្នកទាំងអស់គ្នា ស្គាល់ពាក្យ ជាតិនិយមទេ?

២២៦ - ឡូយណាស់ទៅអី ចេះនិយាយរឿងនយោបាយហ្នឹង? អ្នកនយោបាយឯណោះ បានគេឡូយ។ គេមានអំណាច មានលុយ បានប្រជាជនគាំទ្រ បានសញ្ញាប័ត្របណ្ឌិត ហើយសូម្បីតែរូបថតគេក៏ស្អាតៗដែរ ហើយចុះអ្នកនិយាយហ្នឹងមានស្អីខ្លះ? ស្តាប់តែពូ កែមឡី ជាមួយលោកគ្រូ សុខទូចនិយាយសោះ ធ្វើឯងអឿអីណា?

២២៧ - បើស្រលាញ់ជាតិ កុំធ្វើជាកូនអុករបស់អ្នកនយោបាយ ឬបក្សនយោបាយ។ បើចង់ធ្វើនយោបាយ យកគម្រូតាម ធី សុវណ្ណថា ព្រោះនោះជាវិធីរបស់អ្នកនយោបាយ ហើយចាំយកគម្រូតាម សម្តេច។ បើខ្លួនឯងស្រលាញ់នយោបាយ កុំមកបោកគេថា ខ្លួនឯងស្រលាញ់ជាតិ។ ជាតិមានតម្លៃជាងនយោបាយឆ្ងាយណាស់ កុំចេះតែថាឱ្យរួចពីមាត់។ នយោបាយជាសិទ្ធិបុគ្គល បើគេមិនចង់និយាយ ក៏មិនមានអីខុសដែរ។

មិនមែនមានតែយើងទេ ដែលចេះស្រលាញ់ជាតិ ឬធ្វើពុតជាស្រលាញ់ជាតិ អ្នកផ្សេងក៏ចេះដែរ គ្រាន់តែគេមិនបញ្ចេញមកក្រៅពេកដូចយើង ថាមិនត្រូវ គេជួយជាតិបានច្រើនជាងយើងផង។

២២៨ - ខ្ញុំសុំនិយាយរឿងនយោបាយបន្តិច។

Page នេះបង្កើតមកក្នុងគោលបំណងដូចនៅលើឈ្មោះអញ្ចឹង គឺ I Like Samkok ប្រែថា ខ្ញុំចូលចិត្តមើលរឿងសាមកុក។ បើគ្រាន់តែយកទៅនិយាយពីនយោបាយ មិនខុសទេ តែបើយកទៅលាបពណ៌ ឬលើកជើងអ្នកនយោបាយ វាខុសធ្ងន់មែនទែន។

យើងយល់ខុសពីពាក្យថា "ប្រជាពលរដ្ឋ ត្រូវចូលរួមក្នុងនយោបាយ"។ ពាក្យនេះ វាច្បាស់ហើយថា យើងមិនអាចគេចពីនយោបាយបានទេ។ គ្រាន់តែយើងធ្វើតាមច្បាប់ចរាចរណ៍ថ្មីហ្នឹង ក៏យើងបានចូលរួមជាមួយនយោបាយរបស់ប្រទេសបាត់ទៅហើយ។ យើងទៅប្តូរអត្តសញ្ញាណប័ណ្ណថ្មីក៏ដោយ ក៏សុទ្ធតែដើរតាមនយោបាយរបស់រដ្ឋាភិបាលទាំងអស់។

តែម្នាក់ៗ មានគិតអញ្ចឹងអី ទៅជានាំគ្នាគិតថា ទាល់តែមួយថ្ងៃៗ យករឿងនយោបាយមកនិយាយ មកវិភាគ ទើបហៅថាចូលរួម។ មិនមែនទេ។ រត់ម៉ូតូឌុប អង្គុយវិភាគនយោបាយ ធ្វើខ្ញុំចិន អង្គុយវិភាគនយោបាយ អត់ការងារធ្វើ អង្គុយវិភាគនយោបាយ ។ បានស្អីមកវិញខ្លះ?

គ្រាន់តែនិយាយ អ្នកណាក៏ចេះដែរ តើបើធ្វើឱ្យចេញជាប្រយោជន៍ មិនប្រាកដទេ។ នៅក្នុងនយោបាយមានរឿងអីខ្លះដែលខ្ញុំត្រូវយកមកនិយាយ

ក្រៅពីរឿង ដេញយួន កាប់ព្រៃឈើ ពុករលួយ បក្សពួកគ្រួសារ ហើយជាពិសេស លើកជើង អំសែន និងអំស៊ី? ហើយយកមកនិយាយធ្វើអី បើគេនិយាយគ្រប់តែគ្នាហើយហ្នឹង?

នៅមានមួយទៀត មិនមែនទាល់តែនិយាយពីនយោបាយ ទើបគេហៅថាស្រលាញ់ជាតិទេ។ កុំគិតថា អ្នកនយោបាយ ស្រលាញ់ជាតិណា ព្រោះបើអ្នកទាំងអស់គ្នា គិតបែបហ្នឹង ស័យធំហើយ។ អ្នកនយោបាយ ស្រលាញ់បក្សរបស់គេ អំណាច ប្រជាប្រិយភាព ភាពមានបាន គ្រួសារ និងខ្លួនឯងតែដោយសារអ្នកនយោបាយមិនអាចគិតតែពីរឿងនេះបាន ទើបពួកគាត់ដាក់ចិត្តខ្លះ មកធ្វើការអភិវឌ្ឍប្រទេស ដើម្បីរក្សាប្រជាប្រិយភាពបន្តទៀត។ បើពួកគាត់ស្រលាញ់ជាតិ ពួកគាត់មិនឈ្លោះគ្នាទេ។ យើងនាំគ្នាទៅគាំទ្រ គេឈ្លោះគ្នា ហើយនៅគិតថាខ្លួនឯងស្រលាញ់ជាតិទៀត។

យើងត្រូវសួរខ្លួនឯង ថា យើងស្រលាញ់ជាតិ ឬស្រលាញ់នយោបាយ ? បើឆ្លើយថា ស្រលាញ់ជាតិ ត្រូវជួយជាតិតាមកម្លាំងដែលយើងមាន ដូចជាពង្រឹងភាសាខ្មែរយើង ជួយខ្មែរគ្នាឯងដែលមិនចេះ (យួនមិនបាច់ជួយទេ ព្រោះពួកវាពូកែជាងយើងទៀត) ឬក៏កុំធ្វើខ្លួនជាអ្នកក្រម្នាក់ទៀត។ បើឆ្លើយថា ស្រលាញ់នយោបាយ ទៅធ្វើអ្នកនយោបាយទៅ។

នយោបាយ និងជាតិ ទាក់ទងគ្នា តែមិនមែនជារបស់តែមួយទេ។ នយោបាយអាចស្លាប់ ជាតិមិនអាចទេ ឬអាចនិយាយបែបនេះ បក្សនយោបាយប្តូរចុះឡើង តែជាតិនៅដដែល។

ចប់ប៉ុណ្ណឹងហើយ ព្រោះខ្ញុំថានិយាយតែបន្តិច។

២២៩ - ធ្វើជាមនុស្សស្រី ត្រូវតែឆ្លាត គ្រប់ថ្ងៃ មិនមែនតែ Valentine Day ហ្នឹងមួយទេ។ បើមិនទាន់ប្រាកដទេ ត្រូវចេះរកលេសខ្លះ ក៏ល្អដែរ។ កុំភ្លេចទុកផ្លូវក្រោយឱ្យខ្លួនឯងផង។ ផ្លូវក្រោយដែលខ្ញុំនិយាយនោះ គឺតម្លៃខ្លួន។

បើអាប្រុសហ្នឹងវាល្អ មិនថាទេ ចុះបើវាល្អតែសម្បកក្រៅ យើងមិិនចប់ទៅហើយ។ បន្ទោសអ្នកណាកើត? បន្ទោសខ្លួនឯងក៏មិនសម បន្ទោសអាប្រុសនោះក៏មិនត្រូវ ។ ប្រុសក៏អាចឆ្លាតបាន ស្រីក៏អាចឆ្លាតបានដែរ។ គ្មានច្បាប់ណាចែងថា មនុស្សស្រីត្រូវតែល្ងង់ជាងមនុស្សប្រុសទេ។ ស្រីៗណាដែលធ្លាប់មើលរឿងសាមកុក គួរតែចេះប្រយ័ត្នខ្លះ ធ្វើដូចក្នុងរឿងហ្នឹងអ៊ីចឹង។

ទុកផ្លូវក្រោយផង។

២៣០ - ធ្វើមើលតែផ្ទះសំណាក់គេបើកតែថ្ងៃ Valentine ។ ធ្វើមើលតែតណ្ហាវាឡើងតែថ្ងៃ valentine ។

ខាងលើនេះជាកំណាព្យដែលខ្ញុំតែង ឃើញវាមានពាក្យ Valentine ស្ទួនគ្នាទេ។

២៣១ - ខ្វះបទពិសោធន៍ ងាយនឹងបរាជ័យណាស់។

២៣២ - រឿងលេងកាត់ពេក ចំណុចខ្លះមើលហើយនៅតែឆ្ងល់ ។ ទាល់តែអានសៀវភៅទើបដឹងអស់។

២៣៣ - ស្តាប់ហានស៊ីននិយាយរឿងមួយឱ្យយើងស្តាប់ ហើយរៀនគិត

ដោយខ្លួនឯង។ "ថ្នាំដូចគ្នា ជនជាតិសុងយកវាមកបោកខោអាវ អ្នកដឹកនាំទ័ពយកវាមកច្បាំងឈ្នះសត្រូវ" ។

# ទំព័រចុងក្រោយ

យើងមកដល់ចំណុចបញ្ចប់នៃសៀវភៅនេះហើយ។ ខ្ញុំសង្ឃឹមថាអ្នកដែលបានអានហើយ នឹងទទួលបានចំណុចណាមួយដែលអាចយកទៅប្រើជាប្រយោជន៍បាន។ ខ្ញុំមិនដឹងថាអ្នកទាំងអស់គ្នាចង់បានអ្វីនោះទេ ដូច្នេះបើអាចយកប្រើត្រឹមតែមួយ ក៏ខ្ញុំអស់ចិត្តដែរ។ ខ្ញុំមិនចង់ធ្វើជាអ្នកនិពន្ធអត់ប្រយោជន៍ដែលសរសេរអ្វីដែលគ្មានបានការនោះទេ ហើយខ្ញុំជឿថាអ្នកទាំងអស់គ្នា ក៏មិនចង់បានឈ្មោះជាអ្នកអានអត់ប្រយោជន៍ដែលចេះតែអាន ហើយគ្មានយកទៅប្រើដែរ។

មានចំណុចសំខាន់ខ្លះនៅក្នុងនេះ ដែលខ្ញុំត្រូវតែរំលឹកអ្នកទាំងអស់គ្នាឱ្យអានឡើងវិញ ដូចជា ជនជាតិយួន សិទ្ធិរបស់អ្នកនិពន្ធ អំណួត និងប្រព័ន្ធដែលយើងកំពុងតែរស់នៅ។ ចំណុចនេះទាំងនេះ អាចជាផ្លូវសម្រាប់អ្នកដែលចង់ដឹងបន្ថែម ធ្វើការស្រាវជ្រាវបន្តទៀតបាន។ សៀវភៅនេះ គ្រាន់តែជាការរំលឹកឡើងវិញ ពីអ្វីដែលខ្ញុំធ្លាប់សរសេរ និងអ្វីដែលអ្នកទាំងអស់គ្នាធ្លាប់បានអាន ហើយមិនចាំប៉ុណ្ណោះ។ ខ្ញុំមិនថាអីទេ ព្រោះសូម្បីតែខ្ញុំដែលជាអ្នកសរសេរខ្លួនឯង ក៏ខ្ញុំមិនចាំអស់ផង។

អ្វីដែលខ្ញុំចង់សូមជាចុងក្រោយ គឺ កុំចែករំលែកសៀវភៅនេះ ដោយគ្មានការអនុញ្ញាតពីខ្ញុំ។ សូមកុំរៀនតាមផេកចោរដែលតែងតែលួចស្នាដៃរបស់អ្នកដទៃមកធ្វើជាប្រយោជន៍មុខមាត់របស់វា។ បើយើងចេះអានសៀវភៅ យើងគួរតែចេះប្រកបពាក្យថា **ចោកទាប** ហើយ។ ការចែករំលែកជារឿងល្អ ប៉ុន្តែបើយើងយករបស់អ្នកដទៃទៅចែករំលែក ហើយធ្វើឱ្យខូច

ប្រយោជន៍គេ វានឹងទៅជារឿងភ្លើវិញមិនខាន។ អ្នកទាំងអស់គ្នាធ្វើបាន តែប៉ុននេះ អ្នកនិពន្ធផ្សេងទៀត នឹងមានសង្ឃឹមសរសេរកាន់តែច្រើន។

ចរិតឆ្កែរបស់ខ្ញុំបានបង្ខំខ្ញុំឱ្យនិយាយតាមត្រង់ថា "បំផ្លាញអ្នកនិពន្ធក្នុងស្រុករបស់ខ្លួន ជាទង្វើរបស់មនុស្សភ្លើប៉ុណ្ណោះ"។ ការ Copy ចែកគ្នា ជាការសម្លាប់អ្នកនិពន្ធដែលរកលុយបានតិចស្រាប់។ កុំភ្លេចណា អ្នកនិពន្ធមិនមែនស៊ីអក្សរឆ្អែតទេ ទោះបីជាពួកគេស្រលាញ់ការសរសេរសៀវភៅប៉ុណ្ណាក៏ដោយ ហើយបើមិនជួយគាំទ្រទេ កុំបំផ្លាញគេ។

# អំពីខ្ញុំ

ខ្ញុំឈ្មោះ ហួត សេងគៀ។ ខ្ញុំធ្វើការក្នុងផ្នែកក្រាហ្វិចឌីហ្សាញ នៅភ្នំពេញនេះឯង។ ក្រៅពីឌីហ្សាញ ខ្ញុំនៅមានចំណូលចិត្តមួយទៀត គឺការសរសេរ។ ខ្ញុំសរសេរប្លុក សៀវភៅ និងនៅលើហ្វេសប៊ុក។

ខ្ញុំចង់យកអ្វីដែលមានក្នុងខួរក្បាលរបស់ខ្ញុំ ឱ្យអ្នកដទៃអាន។ ខ្ញុំមានអារម្មណ៍ថា ក្បាលខ្ញុំរីកធំ បើខ្ញុំដឹងអ្វីហើយ មិនយកវាចេញមកក្រៅ។ ខ្ញុំមិនចង់បានក្បាលធំពេកទេ ពិបាកពាក់មួកសុវត្ថិភាព។

សូមអរគុណអ្នកទាំងអស់គ្នាដែលមិនប្រកាន់ខ្លួនអានសៀវភៅរបស់ខ្ញុំ។ ការអានរបស់អ្នករាល់គ្នា ជាការផ្តល់កម្លាំងចិត្តដល់ការសរសេររបស់ខ្ញុំ។